# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែឧសភា លេខ ៥

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — វិភទូបសមកថា ................ | ព្រះភិក្ខុ ហេន- ធឿង ....... | ៣២៣ |
| — បញ្ចាសជាតក ភាគទី ២ (តមក) .... | បណ្ឌិតមហា ឈឹម-ស៊ុម ..... | ៣៣៣ |

ផ្នែកអក្សរសាស្ត្រ

| | | |
|---|---|---|
| — រឿងសៅរ៍សោយ .............. | ព្រះមហាឧត្តមវិជ្ជា ប៉ង់-ប៉ម ... | ៣៥១ |
| — រឿងសាមកុក (តមក) ........... | ឧកញ៉ា នូ- កន ... .... | ៣៥៨ |
| — ទាលៈនឹងទមយន្តី (តមក) ........ | អ្នកស្រី ស្រ៊ុន-សារីយ៉ាន់ .... | ៣៦៣ |
| — ដំណើរអស្ចារ្យនៃលោកភ៉ីស្សូប៊ីយូយេ (តមក) .................. | លោក ភ៉ុយ -ប៊ុក ......... | ៣៧០ |
| — ដំណឹងតាមខ្យល់ក្នុងកត្តារៈ (តមក) .... | លោក ផេង-ជ្រីវ ......... | ៣៧៩ |
| — ការសន្ទនាពីសិល្បៈខ្មែរលើកទី ១—២ ... | លោក ជាប-ពិន ........ | ៣៨៧ |

កំណត់នឹងប្រវត្តិការណ៍

| | | |
|---|---|---|
| — ការប្រឡងបេក្ខបព្វជិត ដែនកូសាំងស៊ីន | ព្រះញាណកោសល ញាណ-ឈឹម | ៣៩៧ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Vivadopasamakatha . . . . . *Brah Bhikkhu HEN-THOEUNG.* 323
— Pannasajataka -vol-II (suite) . *M. CHHIM-SOUM . . . . . .* 333

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne . . . . . . . . *Brah Maha PEUNG-PAM . . .* 351
— Histoire de Samkok (suite) . . *Oknha NOU-KAN . . . . . .* 358
— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN . . .* 363
— Le voyage extraordinaire de VASIOBIOYÉ (suite) . . . . . *M. RAY-BUC . . . . . . . . .* 370
— Le souffle du désert (suite) . *M. PHENG-CHRIV . . . . . .* 379
— Sur les Beaux-Arts khmèrs . . *M. CHAP-PIN . . . . . . . .* 387

NOTES ET CHRONIQUES:

— Examan des éléves religieux en Cochinchine . . . . . . . . *Vén. NHEAN-CHHOEUN . . .* 398

Prix d'abonnement annuel (comprenant 12 numéro) 200$

# វិវាទូបសមកថា

## ព្រះភិក្ខុ ហេង-ធឿង វត្តមហាមន្ត្រី

*រៀបរៀង*

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ) ។*

*ក្នុងឱកាសនេះ អាត្មាភាពសូមសំដែងអំពី "វិវាទូបសមកថា" ពណ៌នាអំពីដំណើរនៃការឈ្លោះវិវាទ និងធម៌ជាបដិបទានៃការកំចាត់បង់នូវសេចក្ដីឈ្លោះវិវាទនោះ ដើម្បីជាគោលបដិបត្តិហាត់ពត់កាយ-វាចា-ចិត្តរបស់សាធុជនពុទ្ធបរិស័ទទាំងឡាយ អ្នកត្រូវការនឹងចេញចាកទុក្ខ ហើយនឹងដើរទៅកាន់ផ្លូវនៃវឌ្ឍនធម៌និងសន្តិសុខ ដូចព្រះពុទ្ធភាសិតដែលមានក្នុងបទគាថាយ៉ាងនេះថា:*

សកញ្ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មតិមាហុ សច្ចន្តិ

ប្រែថា "សមណព្រាហ្មណ៍ពួកខ្លះ ពោលសរសើរធម៌របស់ខ្លួនថាពេញបរិបូណ៌ ពោលបង្អាប់ធម៌របស់ជនដទៃថាទាបថោក, ពោលសទ្តិលទ្ធិរបស់ខ្លួន ៗ ថាជាគុណជាតិពិតប្រាកដ, សមណព្រាហ្មណ៍ពួកនោះរមែងឈ្មោះប្រកែកគ្នាដោយហេតុយ៉ាងនេះឯង" ៗ

អធិប្បាយថា ប្រជុំជនដែលរួមគ្នានៅក្នុងផ្ទៃលោកនេះ ទោះគ្រហស្ថក្តី បព្វជិតក្តី នឹងនៅជាសុខព្រមព្រៀងគ្នាបាន មិនទាស់ទែងឈ្មោះវិវាទ បែកសាមគ្គីគ្នា ក៏ដោយសារមានគុណធម៌អាស្រ័យប្រចាំនៅជាប់ក្នុងសន្តាន គឺអ្នកធំតាំងនៅក្នុងសេចក្តីអាណិតមេត្តាត្រាប្រណីឧបអរសាទររីករាយក្នុងចំណែកដែលអ្នកតូចគួរទទួលបាន មិនសំដែងអាការខ្ពស់ទាប មិនលំអៀង ព្រោះឆន្ទាគតិជាដើម, ដល់គ្រាដែលអ្នកតូចធ្វើខុស ក៏ពិចារណារកទោសហើយផ្គូផ្គងអប់រំឲ្យរឹងប៉ុងនឹករកសេចក្តីខុស, ដល់គ្រាអ្នកតូចធ្វើត្រូវក៏បណ្តោះសេចក្តីទុកចិត្តលួមឲ្យកើតឆន្ទៈ តែកុំឲ្យមានអតិមានៈក្នុងករណីនោះ ៗ ចំណែកអ្នកតូចត្រូវតាំងនៅក្នុងជេដ្ឋាបចាយនធម៌ បដិបត្តិកោតក្រែង ឱនលំទោនចំពោះលោកអ្នកធំ ជាប្រមុខរបស់ត្រកូល ប្រមុខរបស់គណៈ, ប្រមុខរបស់ប្រជាកស្ត្រ-ប្រទេសជាតិ ដោយជឿស្តាប់ពាក្យឱវាទ ដាស់តឿនក្រើនរំលឹកក្នុងវិធីបដិបត្តិល្អ មិនលើកខ្លួនវាយឫកស្មើនឹងលោក មិនរឹងត្អឹងចចេសទាស់ បង្កបង្កើតអធិករណ៍ផ្សេង ៗ បដិបត្តិអនុវត្តតាមចំណែកនៃករណីយកិច្ចដែលមិនមានទោស ព្យាយាមធ្វើខ្លួនឲ្យជាមនុស្សគួរគេអាណិត ជាមនុស្សប្រេះធ្វើខ្លួន

ឲ្យគេស្រឡាញ់ ៗ បើមនុស្សដែលនៅរួមពួក-គណៈ បែរត្រឡប់ជាមានទិដ្ឋិយល់ឃើញផ្សេងគ្នាទាស់លើសប្រមាណ គឺអ្នកធំមិនមានការទុកចិត្តកូនក្រុមអ្នកតូច ៗ ក៏មិនគោរពជឿស្តាប់អ្នកធំ, កាលបើយ៉ាងនេះ គណៈក្រុមសង្គមនោះ ៗ ក៏នឹងទៅកាន់ហាយនធម៌ សេចក្តីសាបសូន្យយ៉ាងឆាប់ ព្រោះមានការយល់ឃើញផ្សេងគ្នាក្នុងករណីសព្វយ៉ាង ដោយអំណាចការប្រកាន់ខ្លួនថាមានជាតិ ត្រកូល យសសក្តិ បរិវារ ភោគសម្បទ សិល្បវិជ្ជា ខ្ពង់ខ្ពស់ជាងគ្នា ព្រមទាំងការគិត ការយល់ឃើញក៏មិនមូលមិត្តរៀបរយជាមួយគ្នា, ហេតុប៉ុណ្ណេះជាដើម ជាគោលជាទីតាំងនៃសេចក្តីឈ្លោះវិវាទទាស់ទែង ជាដម្លោះឲ្យមានការបែកសាមគ្គីធម៌ ហូរចូលមកជាលំដាប់ សមដូចពុទ្ធភាសិតដែលលើកមកទុកជានិក្ខេបបទក្នុងខាងដើមថាៈ "សកញ្ហិ ធម្មំ បរិបុណ្ណមាហុ សមណៈព្រាហ្មណ៍ពួកខ្លះពោលសរសើរគុណធម៌របស់ខ្លួនថាជាគុណជាតបរិបូណ៌" ៗ ពាក្យថា "សមណៈព្រាហ្មណ៍" នោះ ត្រង់សមណៈ មតិផ្លូវព្រះពុទ្ធសាសនាពោលសំដៅ លោកអ្នកស្ងប់រម្ងាប់កាយ-វាចា-ចិត្ត ចាកអកុសលធម៌ដោយប្រព្រឹត្តតាមធម៌វិន័យបរិយាយបដិបត្តិចាត់ទុកជាពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាតដែលជាច្បាប់បែកខាងផ្លូវព្រះពុទ្ធសាសនា ឈ្មោះថា សមណៈ ៗ ត្រង់ "ព្រាហ្មណ៍" នោះកាលបើពោលដោយបរិយាយ បានដល់បុគ្គលមួយពួក ដែលមានបដិបទាមានការចេះដឹង ការយល់ និងការសិក្សាសិល្បវិជ្ជាទំនាស់គ្នានឹងផ្លូវព្រះពុទ្ធសាសនា ដោយការរាប់អាន បូជាព្រះឥស្សូរ

ជាដើម, សេចក្ដីបដិបត្តិរបស់គេដែលប្រព្រឹត្តទៅដើម្បីអង្វរព្រះឥស្សរ ដោយការយល់ឃើញថាសុខសម្បត្តិ - សុវត្ថិភាព ដែលមនុស្សត្រូវបាន ត្រូវសោយ សុទ្ធតែព្រះឥស្សរលោកឲ្យកើតឲ្យមានទាំងអស់, កាលបើពួក ព្រាហ្មណ៍មានការយល់ថា ព្រះឥស្សរជាម្ចាស់ប្រោសប្រាណប្រគល់សុខ-សម្បត្តិដល់ខ្លួន ដោយយញ្ញវិធីបែបណា ពួកគេក៏រៀបចំយញ្ញវិធីបែប នោះ, ការធ្វើពិធីវត្ថុបំណេះ ក៏សុទ្ធតែប្រាថ្នាយកសេចក្ដីសុខ ចំរើន ទាំង អស់ ៗ មួយទៀត, តាមន័យខ្លះ លោកកំណត់យកបុគ្គលមានប្រភេទ តែមួយបែប គឺសំដៅយកអ្នកប្រព្រឹត្តចរិយាវត្តតែមួយដូចគ្នា ជាអ្នកមាន វត្តប្បដិបត្តិ ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ស្ងាត់ មិនបៀតបៀនសត្វឲ្យ បានទទួលសេចក្ដីក្ដៅក្រហាយ ហៅថា សមណព្រាហ្មណ៍ទាំងអស់ ៗ ឯសមណព្រាហ្មណ៍ពួកនេះ ប្រសិនបើមានការសិក្សាសិល្បវិជ្ជា, អក្សរ-សាស្ត្រ, សាសនសាស្ត្រ, បវត្តិសាស្ត្រ, តក្កសាស្ត្រ, ធម្មសាស្ត្រ ជាមួយគ្នា តែមានការយល់ឃើញឃ្លាងអំពីគ្នា គង់ក្លាយទៅជាស្រមោល ជាប់តាមខ្លួន, បើប្រព្រឹត្តទៅដោយសេចក្ដីក្លាហាន មិនមានបញ្ញាជា គ្រឿងលុបលាងចោលទេ មុខជានឹងបណ្ដាលឲ្យមានបែកសាមគ្គីធម៌ កើតមានដល់គ្រួសារ ពួក គណៈបាន កាលបើយ៉ាងនេះ អនត្ថកម្ម (អំពើមិនចំរើន) អាចលូតលាស់ឡើងយ៉ាងធំ ។

តាមគតិលោក ដូចគ្នងគ្រួសារ១ បើកើតវិវាទ ទាស់ទែងគ្នា ដោយការ យល់ឃើញខុសគ្នា ប្រកាន់ថា ខ្លួនមានអំណាចច្រើនជាង មានសេចក្ដី

បេះដូង អង់អាច ក្លាហានជាង ស្វាមីប្រកាន់ថា ល្អជាងភរិយា។ មិនព្រមទទួលគោរពដល់ស្វាមី ដោយការប្រកាន់ថា ខ្លួនមានត្រកូលខ្ពស់ជាង, មានភោគសម្បូរច្រើនជាង មានគុណសម្បត្តិសមត្ថភាពពូកែជាង, ស្វាមីយ៉ាងនេះ ភរិយាយ៉ាងនោះ សេចក្ដីសុខសប្បាយត្រឹមតែថ្ងៃមួយក៏ពិបាកនឹងមាន មានតែការប្រទាំងប្រទើសគ្នាជាប់ជានិច្ច ទីបំផុតទាល់តែបែកចាកភាពជាស្វាមី-ភរិយាទៅក៏មាន ព្រោះតែមានទិដ្ឋិមានះប្រកាន់ខុសគ្នា មិនមានត្រាប្រណីអត់អោនរកគ្នា, នេះជាផ្លូវវិនាសចំពោះគ្រួសារដែលជាចំណែកយ៉ាងតូចតាច ។ បើសំដៅយកប្រជុំជនដែលជាចំណែកធំ បានដល់ប្រទេសជាតិ ហាយនធម៌កើតតែលូតលាស់ឡើងដោយចំណែកយ៉ាងធំ ។ បុគ្គលមានមានះប្រកាន់ខ្លួន សូម្បីតែញាតិរបស់ខ្លួនក៏គង់ប្រមាថមើលងាយដែរ បុគ្គលបែបនេះឈ្មោះថាដុតបំផ្លាញកម្ទាំងរបស់ជាតិត្រកូលនៃខ្លួនឯង បើកចំហនោះឲ្យសេចក្ដីវិនាសហូរចូលបាន, សមដោយពុទ្ធភាសិតដែលមានក្នុងបរាភវសូត្រថា:

ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ប យោ នរោ
សញ្ញាតិមតិមញ្ញេតិ តំ បរាភវតោ មុខំ

ប្រែថា "នរជនដែលរឹងរូសព្រោះជាតិ, រឹងរូសព្រោះទ្រព្យ, រឹងរូសព្រោះគោត្រ តែងមើលងាយញាតិរបស់ខ្លួន, នេះជាប្រធាននៃសេចក្ដីវិនាស" ។

តាមគតិធម៌ សមណព្រាហ្មណ៍ដែលមានការរស់នៅជាប់ដោយផនដៃ ចេញចាកគេហដ្ឋាន ប្រព្រឹត្តអនាគារិយ៍ ទីងជាទីគោរពកប់អានជ្រះថ្លារបស់ប្រជាជន ព្រោះមានសំរេះគងធម៌បរិបូណ៌ត្រឹមត្រូវ មានបដិបទាដើរទៅរកសន្តិសុខ មិនបានទំលាយសាមគ្គីធម៌របស់ពួកគណៈ សមាទានមាំក្នុងសីលាចារវត្ត ជាបដិបទារបស់សមណៈដែលរួមបូលក្នុងគុណសម្បត្តិ ២ ប្រការគឺៈ ទិដ្ឋិសាមញ្ញតា ភាពជាអ្នកស្មើគ្នាដោយការយល់ឃើញ ១ សីលសាមញ្ញតា ភាពជាអ្នកស្មើគ្នាដោយសីល ១ ។ គុណសម្បត្តិ ២ ប្រការនេះជាហេតុចងផ្សារភ្ជាប់នឹងសេចក្តីស្និទ្ធស្នាលមិត្តមួល ក្រៀកភ្ជាប់នឹងអធ្យាស្រ័យរបស់ពួកគណៈទុកបាន មិនបានឈ្លោះវិវាទ ។ រីឯសេចក្តីឈ្លោះវិវាទគ្នា សូម្បីត្រឹមតែបន្តិចបន្តួច ក៏រមែងមិនជាទីសរសើរនៃវិសេសជនទាំងឡាយមានព្រះពុទ្ធជាដើមឡើយ គួយ៉ាង ដូចភិក្ខុអ្នកនៅក្នុងក្រុងកោសម្ពីជំនាន់ពុទ្ធកាល ព្រះវិនយធរនេះ្ដៀ សនឹងព្រះធម្មកថិក ដោយហេតុត្រឹមតែសល់ទឹកជំរះអាចមន៍ទុកក្នុងវច្ចកុដិ ហើយតិះដៀលថា ទុកណាជាត្រូវអាបត្តិហើយនៅតែមិនស្គាល់អាបត្តិ ហើយបានប្រាប់សេចក្តីទោសប្រហែសរបស់ធម្មកថិក ដល់ពួកនិស្សិតរបស់ខ្លួន ។ ចំណែកខាងពួកនិស្សិតរបស់ព្រះធម្មកថិកដឹងច្បាស់រឿងនោះ ក៏តូចចិត្ត, ភិក្ខុទាំងពីររូបសុទ្ធតែមានសិស្សគណច្រើន ទើបសំដែងសេចក្តីតូចចិត្តដល់គ្នានឹងគ្នា សេចក្តីឈ្លោះវិវាទនោះ

បានរៀលដាលផ្ទុះចេញទៅដល់ពួកទាយក ទាយិកា ទេវតា-មារ-ព្រហ្ម បែកគ្នាទៅជាពីរចំណែក សូម្បីសម្តេចព្រះទសពលញាណក៏ទ្រង់រំលាងព្រះទ័យ ទើបស្តេចចេញទៅព្រៃរក្ខិតវ័ន ដើម្បីស្វែងរកសន្តិវិសុខ, រឿងនេះលម្អជាផ្លូវសន្និដ្ឋានថា អ្នកមានមានៈទិដ្ឋិប្រកាន់ខ្លួនថា មានការចេះដឹងអង់អាចប្រសើរជាងបុគ្គលដទៃ ពាល់តែហួសប្រមាណ រមែងកសេចក្តីក្តៅក្រហាយឲ្យចំរើនឡើងដល់ពួកគណៈ ដោយប្រការយ៉ាងនេះ, ព្រោះហេតុនោះ សម្តេចព្រះមហាមុនីទ្រង់ប្រកាសសន្តិវរបទអមតធម៌ ទើបបានត្រាស់ប្រដៅពួកពុទ្ធបរិស័ទ ទាំងគ្រហស្ថទាំងបព្វជិតឲ្យមានការគិតឃើញត្រូវគ្នា ដោយគន្លងធម៌ជាគោលនៃការបដិបត្តិ ដើម្បីកំចាត់មានៈទិដ្ឋិចាកសន្តាន ព្រោះថាសេចក្តីស្ងប់នេះ ចាត់ទុកជាគុណសម្បត្តិដ៏សំខាន់ក្នុងគតិលោកគតិធម៌ អាចឡើងទៅកាន់ភាពនៃវឌ្ឍនធម៌បាន ។

សេចក្តីស្ងប់ទឹងកើតមានដល់ពួក-គណៈ ក៏ត្រូវអាស្រ័យបុគ្គលមានការហាត់ពត់កាយ-វាចា-ចិត្តក្នុងខន្តីគុណ មិនជាមនុស្សឆេវឆាវឆាប់ក្រោធខឹងមិនញាប់ញ័រចំពោះភ័យន្តរាយ ទុកដាក់ខ្លួនជាកណ្តាលឲ្យសមដល់ឋានៈ មានសតិមិនលើកដំកើងខ្លួន មិនប្រកាន់វត្ថុណាមួយក្នុងលោកនេះថាជារបស់ខ្លួន បើទុកជាត្រាត់ប្រាសចាកវត្ថុនោះ ក៏មិនសូវមានសេចក្តីសោកស្តាយប៉ុន្មាន ព្រោះសព្វសង្ខារតែងតែសូន្យទៅ

ទីងមិនធ្លាក់ទៅក្នុងអតតិធម៌ទាំងឡាយ ដូច្នេះ ទើបតាំងនៅក្នុងសន្តិភាព មិនវិវាទតាស់ទែងគ្នាបាន ព្រោះមានបដិបទាដើរទៅកាន់ធម្មប្បដិបត្តិ ។

ចំណែកខាងបុគ្គលអ្នកធ្លាក់ចុះនៅក្នុងអំណាចទិដ្ឋិមានះ កាលបើមានវិជ្ជាការចេះដឹង ក៏ច្រើនតែមានសេចក្តីយល់ឃើញថា ខ្លួនមានគុណសម្បត្តិ សមត្ថភាពជាងបុគ្គលដទៃ លើកដំកើងតែខ្លួនឯងមើលងាយគេ, បុគ្គលបែបនេះឈ្មោះថាផ្សាំបណ្តុះពូជនៃការមិនគាប់ចិត្តបុគ្គលឯទៀត, បើទុកជាដំណើរខុស ដែលជនដទៃស្តីប្រដៅស្រាវរកការត្រូវ, ក៏គង់ប្រឹងជជែកតស៊ូយកជ័យជំនះទីងការពារខ្លួន; ព្រោះហេតុនោះ ការឃើញខុសជាហេតុឲ្យជជែកតក៏គ្នា ទើបបាត់ជាមូលហេតុនៃវិវាទ ។ មួយវិញទៀត បុគ្គលអ្នកឃើញវិបរិតមានចិត្តប្រកួតប្រកាន់ដោយមានះ រមែងសំគាល់វត្ថុមិនមែនជាសារៈថាមានសារៈ សូម្បីវត្ថុត្រឹមតែកើតឡើងដោយសន្មតិ ក៏គង់ថាវត្ថុពិតប្រាកដទៀងទាត់ ទាំងច្រើនសំដែងលទ្ធិនោះ ឲ្យបុគ្គលដទៃជឿស្តាប់បដិបត្តិតាមដូចប្រដៅថាលោកនេះ ជារបស់ទៀងជាដើម ដោយប្រាសចាកហេតុផលជាគ្រឿងអាង ព្រោះតាមការដែលពិត ពាក្យថាលោក ៗ នេះ ដោយសន្មតិកំណត់យកបញ្ចក្ខន្ធ ដែលធ្លាក់ចុះលុះក្នុងអំណាចជរា - ព្យាធិ - មរណៈ មានការកើតជាដើមចម មានការផ្លាស់ប្តូរប្រែប្រួលទៅជាកណ្តាល មានការបែកធ្លាយប្រេះឆាទៅជាទីបំផុត, ដែលលោកហៅថាសត្វបុគ្គល ក៏

ព្រោះសន្តតិតាមលោកវោហារយ៉ាងនេះឯង, បើហៅដោយខ្លីថាបញ្ចក្ខន្ធ គឺធាតុ ៤ : ដី, ទឹក, ភ្លើង, ខ្យល់ ផ្សំផ្គុំចូលគ្នាជារូប-វេទនា-សញ្ញា-សង្ខារ-វិញ្ញាណ អាស្រ័យនឹងគ្នា; កាលបើបច្ច័យគឺធាតុ ៤ អស់កម្លាំងផ្គុំផ្គុំគ្នាហើយ លោកគឺបញ្ចក្ខន្ធក៏នឹងតាំងនៅមិនបាន ត្រូវបែកធ្លាយទៅតាមបច្ច័យនោះដែរ, សមតាមទិព្វពុទ្ធភាសិតថា យថា បច្ចយំ បវត្តតិ "របស់សព្វយ៉ាងដែលបច្ច័យប្រជុំផ្គុំឡើង រមែងប្រព្រឹត្តទៅតាមបច្ច័យ" ៗ ដូច្នេះ អ្នកដែលថាបញ្ចក្ខន្ធជារបស់ទៀងទាត់ ឈ្មោះថាខារទាំងពកាំងការឃើញត្រូវរបស់ជនដទៃ ដោយប្រាសចាកហេតុផល ព្រោះអំណាចទិដ្ឋិមានះ ចូលលុកលុយគ្របសង្កត់សន្តានៈដោយរឹងប៉ឹងមិនព្រមរកហេតុផលក្នុងការយល់ឃើញរបស់អ្នកដទៃ ប្រកាន់មាំ ឈ្លក់ស៊ប់ក្នុងការយល់ឃើញរបស់ខ្លួន លើកដម្កើងធម៌គឺការចេះដឹងរបស់ខ្លួនថាជារបស់ពិត ឯការយល់ឃើញរបស់បុគ្គលដទៃថាមិនពិត ដោយមិនមានអាងហេតុផល ព្រោះហេតុនោះឯង ការយល់ឃើញរបស់បុគ្គលបែបនេះ ទើបមិនប្រព្រឹត្តទៅដើម្បីសន្តិភាព សមសុខ, ទាំងមិនអាចធ្វើខ្លួននឹងបុគ្គលដទៃឲ្យដើរទៅកាន់ភូមិនៃវឌ្ឍនធម៌ នឹងការ្យធម៌បានទេ, មានតែប្រព្រឹត្តដើម្បីបំផ្លាញសាមគ្គីធម៌ ឲ្យបែកបាក់ឃ្លាតឃ្លាចាកគ្នា ទៅជាច្រើនពួក-ក្រុម នឹងជាហេតុសេចក្តីឈ្លោះវិវាទ ទាស់ទែងគ្នាឲ្យចំរើនឡើងជាលំដាប់ ជាហេតុប្រានខ្លួនឯងនឹងបុគ្គលដទៃទាំងពួកគណៈឲ្យធ្លាក់ទៅកាន់

សេចក្តីទុក្ខក្តៅក្រហាយជានិរន្តរ៍ដោយពិត, សមដូចពុទ្ធភាសិតដែលបានលើកទុកជានិក្ខេបបទក្នុងខាងដើមថា:

សកញ្ហិ ធម្មំ បរិបុណ្ណមាហុ
អញ្ញស្ស ធម្មំ បន ហីនមាហុ
ឯវម្បិ វិគ្គយ្ហ វិវាទយន្តិ
សកំ សកំ សម្មតិមាហុ សច្ចន្តិ ។

សមណព្រាហ្មណ៍ពួកខ្លះ ពោលសរសើរធម៌របស់ខ្លួនថា ពេញបរិបូណ៌. ពោលបង្អាប់ធម៌របស់ជនដទៃថាទាបថោក, ពោលសន្មតិលទ្ធិរបស់ខ្លួនៗ ថាជាគុណជាតិពិតប្រាកដ, សមណព្រាហ្មណ៍ពួកនោះរមែងឈ្លោះប្រកែកគ្នាដោយហេតុយ៉ាងនេះឯង ។

កាលបើពួកពុទ្ធសាសនិកបរិស័ទ បានជ្រាបអត្ថនៃភាសិតនេះហើយ សមគួរនឹងបដិបត្តិឲ្យសមដល់ឋានៈ នឹងជាទីគោរពសក្ការៈរាប់អានរបស់ប្រជុំជន នឹងបានទទួលសេចក្តីសុខ-ចំរើន ទៅតាមផ្លូវវឌ្ឍនធម៌នឹងអារ្យធម៌ សមគួរដល់ការបដិបត្តិ សមសេចក្តីប្រាថ្នាក្នុងវត្តដែលមិនលើសវិស័យសព្វយ៉ាង ដូចបានពណ៌នាមកក្នុងវិភាគរូបសមកថាតាមពុទ្ធបរិហារ ល្មមសមគួរដោយប្រការយ៉ាងនេះ

ឯវំ សមគួរតាមកាលវេលាត្រឹមប៉ុណ្ណោះឯង ។

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## សិរីចុឡាមណិជាតកទី ៧

( និយាយអំពីពាហិរកទាន និងអជ្ឈត្តិកទាន )

លោកអាចារ្យ ឈឹម - ណាក ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

---

ទទាមិ ន វិកម្បាមីតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទានបារមឹ អារព្ភ កថេសិ ។ *សត្ថា រីអង្គសម្តេចព្រះសព្វជ្ញបរមសាស្តាចារ្យ កាលទ្រង់ប្រថាប់នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវទានបារមីរបស់ព្រះអង្គ ហើយទ្រង់សំដែងព្រះធម៌ទេសនា មានបទព្រះបាលីថា:* " ទទាមិ ន វិកម្បាមិ *ដូច្នេះជាដើម ។*

*សេចក្តីដំណាលថា: ថ្ងៃ ១ ភិក្ខុទាំងឡាយ កំពុងតែអង្គុយប្រជុំចរចាទៅមករកគ្នាថា "ម្នាលអ្នកដ៏មានអាយុទាំងឡាយ, ព្រះបរមគ្រូនៃយើងទាំងឡាយ ព្រះអង្គឥតប្រកបស្អប់ស្អល់ក្នុងការបរិច្ចាគទានសោះហ្ន៎!. កាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ទ្រង់បានបរិច្ចាគ*

ទានជាច្រើនណាស់ទៅហើយ, បានទាំងលះបង់ជីវិតរបស់ព្រះអង្គឲ្យទៅជាទានដល់សូមយាចកផង, ព្រះអង្គបានបរិច្ចាគទានដ៏ឧត្តមថ្លៃថ្លាកម្រនរណាធ្វើដូចបាន សូម្បីព្រះអង្គបានត្រាស់ប្រាកដជាព្រះពុទ្ធក្នុងលោកហើយ ក៏បានប្រទានអរិយមគ្គដល់ពួកអរិយសាវ័កទៀត, ប៉ុណ្ណឹងហើយក៏នៅតែមិនទាន់ពេញចំណង់ក្នុងព្រះទ័យនៅឡើយ" ។

គ្រានោះ សម្តេចព្រះជិនស្រី ទ្រង់និមន្តមកកាន់ទីប្រជុំភិក្ខុទាំងឡាយនោះហើយត្រាស់សួរថា: "ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយអង្គុយជុំគ្នានិយាយរឿងអ្វី?" ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា: "បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះអង្គប្រជុំនិយាយសរសើរអំពីព្រះទ័យរបស់ព្រះអង្គដែលនៅមិនទាន់ស្កប់ស្កល់ក្នុងការបរិច្ចាគទាន" ។ សម្តេចព្រះដ៏ទ្រង់ញាណ ទើបទ្រង់ត្រាស់ថា: "ម្នាលភិក្ខុទាំងឡាយ, តថាគតមិនមែនទើបតែនឹងឲ្យទានក្នុងកាលឥឡូវនេះទេ. កាលពីដើម ដែលតថាគតនៅជាពោធិសត្វនៅឡើយ. តថាគតបានទាំងឲ្យសរីរៈពាក់កណ្តាលដល់សូមយាចកផង" ទ្រង់ត្រាស់តែប៉ុណ្ណេះហើយ ក៏គង់នៅស្ងៀម ។ ភិក្ខុទាំងឡាយ នាំគ្នាអារាធនាសូមឲ្យព្រះអង្គនាំអតីតនិទានមកសំដែងប្រាប់, ព្រះអង្គទើបនាំអតីតនិទានមកសំដែងដូចមានតទៅថា:

ម្នាលភិក្ខុទាំងឡាយ, ក្នុងកាលដែលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមសិរីចូឡាមណី សោយរាជសម្បត្តិក្នុងក្រុង

ពារាណសី ។ អគ្គមហេសីរបស់ព្រះអង្គ ទ្រង់ព្រះនាមបទុមវតី ជាស្រីបរិបូណ៌ដោយសីលនិងអាចារៈ, មានបុណ្យបានធ្វើទុកមកពីព្រេងនាយ, មានព្រះកាយដ៏សមរម្យក្រៃពេក ជាទីស្រឡាញ់នៃជនទាំងឡាយ ។ ព្រះរាជានោះ មានព្រះរាជបុត្រាមួយព្រះអង្គទ្រង់ព្រះនាមបទុមកុមារ ។ ឯព្រះរាជាទ្រង់សោយរាជ្យប្រកបដោយធម៌, បានចំណាយព្រះរាជទ្រព្យឲ្យជាងសង់សាលាសម្រាប់ឲ្យទាន ៦ ខ្នង គឺបួនខ្នងនៅទៀបទ្វារព្រះនគរ, ពីរខ្នងនៅពាក់កណ្ដាលនគរក្បែរព្រះរាជដំណាក់, ហើយតែងទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ៦ សែនកហាបណៈ រាល់ៗថ្ងៃ ដូចជាមហាមេឃបង្អុរចុះនូវគ្រឿងដ៏ជោកជាំជានិច្ច ក្នុងវេលាដែលព្រះរាជាអង្គនោះ មានកិត្តិស័ព្ទល្បីខ្ចរខ្ចាយទៅថាជាអ្នកជ្រះថ្លាក្នុងការបរិច្ចាគទាន ។

លំដាប់នោះ, ព្រះរាជាកំពុងតែទ្រង់ប្រទានឱវាទដល់ជនទាំងឡាយមានអាមាត្យជាប្រមុខក្នុងវេលាបុព្វណ្ហសម័យថា “ចូរអ្នករាល់គ្នាឲ្យទានរក្សាសីល តាមសេចក្ដីសប្បាយ, ចូរទ្រទ្រង់នូវឧបោសថសីល” ហើយទ្រង់ស្រង់ព្រះឧទកធារា ដែលអប់ដោយគ្រឿងគន្ធពិដោរមានក្លិនក្រអូបសាយ គួរឲ្យជនផងទាំងឡាយត្រេកអរក្រៃពេក ហើយស្ដេចទ្រង់ព្រះពស្ត្រប្រដាប់ដោយគ្រឿងអលង្ការគ្រប់បែប មានអាមាត្យជាច្រើនហែហមជាបរិវារ ស្ដេចឡើងគង់លើព្រះទីនាំងគជេន្ទ្រជាមង្គលឈ្មោះបុណ្ឌរីកៈ ចេញសំដៅទៅទានសាលា ដល់ហើយទ្រង់ព្រះរាជទានព្រះ

ក៏ជទ្រព្យដល់ស្មូមអ្នកចាំទទួលបាន ដោយព្រះហស្តរបស់ព្រះអង្គ ។ តមកទ្រង់ត្រាស់ព្រះរាជបញ្ជាប្រាប់ពួកអាមាត្យទាំងឡាយថា "ចូរអ្នកទាំងឡាយឲ្យទានតាមទំនងនេះចុះ" ទ្រង់ប្រគល់ការឲ្យទាននោះដល់អាមាត្យទាំងឡាយហើយស្តេចឡើងគង់លើព្រះរាជទីនាំង យានត្រឡប់ទៅក្នុងព្រះបរមរាជវាំងវិញ ។ វេលាបច្ចូសសម័យថ្ងៃមួយ ព្រះរាជាទ្រង់តើនចាកសយនាក្រឡាព្រះបន្ទំ ទ្រង់គង់នៅតែមួយព្រះអង្គទ្រង់មានព្រះដម្រិះថា "អញចង់ឲ្យអជ្ឈត្តិកទាន តែស្មូមយាចកទាំងឡាយសូមតែពាហិរកទានដូច្នេះ, បើសិនជាមានអ្នកណាមកសូមអជ្ឈត្តិកទាន គឺភ្នែកក្តី ក្បាលក្តី បេះដូងក្តី ឈាមក្តី ឬក៏សរីរៈទាំងមូលក្តី អញនឹងធ្វើសរីរាវយវៈទាំងនោះឲ្យជាបច្ច័យនៃសព្វញ្ញុតញ្ញាណ ហើយឲ្យដល់អ្នកនោះពុំខាន" ។ កាលដែលព្រះរាជាកំពុងត្រិះរិះក្នុងព្រះចិន្តាដូច្នេះ ក៏ស្រាប់តែផែនដី កម្រាស ២ សែន ៤ ម៉ឺនយោជន៍ កម្រើកញាប់ញ័រ កម្រាមដូចជាដំរីចុះប្រេង, ទាំងស្តេចភ្នំឈ្មោះសិនេរុ ក៏ឱនលំទោនដូចជាចុងផ្តៅដែលបុគ្គលពេលក្លើងពត់ មានមុខបែរទៅរកនគរពារាណសី; ទាំងមហាសមុទ្រក៏បង្កើតជារលកបោកបែកផ្កាត្រែង ទាំងមហាមេឃក៏បង្អុរមកនូវភ្លៀងបោក្ខរព័ណ៌បញ្ចេញផ្គររន្ទះ ផ្លេកបន្ទោរពុំដូចកាលភ្លឺព្រានព្រាយ; សម្តេចព្រះសក្កទេវិន្ទពិន្ទអមរា ក៏ទ្រង់ទះព្រះហស្តឲ្យសព្ទសាធុការ, ទេវតាទាំងឡាយក្នុងឆកាមាវចរសួគ៌ាក៏ថ្វាយសព្ទហា

ធុការាគារ. មហាព្រហ្មក៏ជួយឲ្យពរជ័យ មានសេចក្ដីជ្រួលជ្រើមក្អកក្អឹក ជាកោលាហល តាំងពីផ្ទៃផែនដីរហូតដល់ព្រហ្មលោក ។

ព្រោះហេតុនោះ បានជាសម្ដេចព្រះសាស្ដាចារ្យទ្រង់ត្រាស់ថា

សិរីបុញ្ញមណិ នាម សោហំ រជ្ជមការយិំ
តទាហំ និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយិំ
ហទយំ ទទេយ្យំ ចក្ខុំ មំសំបិ រុធិរំ បិច
ទទេយ្យំ កាយំ សាវេត្វា យទិ កោចិ យាចេយ្យ មំ
សភាវំ ចិន្តយន្តស្ស អកម្បិ តមសណ្ឋិតំ
អកម្បិ តត្ថ បឋវី សិនេរុវនដំសកាតិ

កាលតថាគតកើតជាស្ដេចឈ្មោះ សិរីបុញ្ញមណិ សោយរាជ្យក្នុងក្រុងពារាណសី. កាលនោះតថាគតអង្គុយលើប្រាសាទ បានត្រិះរិះថានឹងឲ្យអជ្ឈត្តិកទាន គឺថានឹងឲ្យបេះដូង ភ្នែក សាច់ ឈាម ឬថាបើមានអ្នកណាមួយមកសូមខ្លួនតថាគត យកទៅធ្វើជាខ្ញុំបម្រើ ក៏តថាគតស៊ូតែទៅធ្វើជាខ្ញុំបម្រើអ្នកនោះដែរ; តថាគតកំពុងតែត្រិះរិះដូច្នេះ ក៏ស្រាប់តែប្រថពីកម្រើកញាប់ញ័រ ទាំងភ្នំសិនេរុក៏ផ្អៀងទោរទន់មករកតថាគត ។

កាលនោះ អាសនៈនៃសក្កទេវរាជក៏សំដែងនូវឧណ្ហាការក្តៅក្តាយឡើង, ទើបសម្តេចព្រះសហស្សន៍យទ្រង់អាវជ្ជនាការពិចារណាថា:

អ្នកណាអេះជាទេវតាឬក៏ជាមនុស្ស ជាអ្នកបូជាគោរពប្រតិបត្តិមាតាបិតា ឬជាអ្នកបានបរិច្ចាគវត្ថុថ្លៃថ្លាឲ្យទៅជាទាន ឬមួយជាអ្នកប្រព្រឹត្តព្រហ្មចារ្យបានជាធ្វើអញឲ្យក្រៈម្រើកចាកអាសនៈដល់ម៉្លេះ ។

កាលទ្រង់រំពឹងដូច្នេះ ក៏ជ្រាបនូវហេតុនោះ មានព្រះទ័យត្រេកអរសោមនស្សដោយក្រៃលែងថា "អើហ្ន៎! ព្រះបាទស៊ីចុឡាមណី ជាពុទ្ធង្កូរបណ្ឌិលពុទ្ធវង្សអង្គសពេជ្ញ ទ្រង់ប្រាថ្នានឹងឲ្យអជ្ឈត្តិកទាន ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គក្នុងកាលជាអនាគតពុំខានឡើយ" ។ សម្តេចព្រះអម្រិន្ទ្រាធិរាជ ទើបទ្រង់ចុះចាកឋានសួគ៌ លះបង់ភេទជាព្រះឥន្ទ្រនិម្មិតអត្តភាពជាព្រាហ្មណ៍ មានរូបរៃមួយចំហៀងដើរពួលមកកាន់ខគរពារាណសី, ចូលទៅអង្គុយក្នុងទីព្រះលានខៃព្រះរាជា លើកដៃក្រាបថ្វាយបង្គំពោលថា "បពិត្រមហារាជ, សូមព្រះអង្គទ្រង់មានជ័យជម្នះឈ្នះអស់សត្រូវ! សូមព្រះអង្គទ្រង់មានជ័យជម្នះឈ្នះអស់សត្រូវ!" ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះសវនាការក្នុពាក្យថ្វាយជ័យហើយ, ទ្រង់ក្រោកចាកអាសនៈក៏ចៀងព្រះនេត្រទតទៅខាងមុខប្រាសាទឃើញព្រាហ្មណ៍មានរូបអន្ធការ ក៏ទ្រង់ស្តេចចុះចាកប្រាសាទមកកាន់សំណាក់

ព្រាហ្មណ៍ ទ្រង់ទតឃើញព្រាហ្មណ៍មានសរីរៈញាប់ញ័រដូច្នោះ ក៏មានព្រះរាជហឫទ័យប្រកបដោយសេចក្ដីមេត្តាយ៉ាងខ្លាំង មិនអាចនឹងទប់ទល់ដំកល់ព្រះអង្គបាន មានព្រះជលនេត្រាហៀរហូរស្រោក ដោយទ្រង់ព្រះសង្វេគក្នុងព្រះរាជហឫទ័យថា “ឱរូបអញអើយ! គង់មានថ្ងៃណាមួយនឹងទៅជាយ៉ាងនោះដែរក៏ពុំដឹង!” ទើបទ្រង់ក៏រំពឹងថា “អាត្មាអញមិនត្រូវសួរព្រាហ្មណ៍នោះអំពីរឿងហេតុអ្វីដទៃទេ, ត្រូវតែសួរអំពីហេតុដែលព្រាហ្មណ៍មកក្នុងទីនេះប៉ុណ្ណោះចុះ” ទើបទ្រង់ត្រាស់ជាគាថាដូច្នេះថា:

អបិ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោសិ មេ រដ្ឋំ[១] តំ មេ អក្ខាហិ បុច្ឆិតោ

ឱព្រាហ្មណ៍ អ្នកឯងមានភេទជាអ្វី? មានហេតុដូចម្ដេច
បានជាមកកាន់ដែនរបស់យើង? ចូរអ្នកឯងប្រាប់ហេតុនោះ
ដល់យើងកុំលាក់ ។

លំដាប់នោះ ព្រាហ្មណ៍ដែលកំពុងមានសរីរៈញាប់ញ័រដោយអំណាចវេទនាដ៏ខ្លាំងមានខ្លួនស្គមស្គាំងក្ដៅក្រហល់ក្រហាយលើកដៃឡើងក្រាបបង្គំទូលយ៉ាងនេះថា “បពិត្រព្រះរាជសម្ភារ, ទូលព្រះបង្គំជាខ្ញុំជាមនុស្សចាស់ជរា មកក្នុងទីនេះ ដើម្បីសូមសរីរៈព្រះអង្គពាក់កណ្ដាល, សូមទ្រង់ព្រះរាជទានកុំខាន ខ្ញុំព្រះអង្គនឹងយកមកបង្ហាប់នឹងសរីរៈពាក់

---

១ អនុប្បត្តោសិ មំ រដ្ឋន្តិបិ បាឋោ ។

កណ្ដាលនៃទូលព្រះបង្គំជាខ្ញុំ, សូមព្រះអង្គប្រទានជីវិតដល់ទូលព្រះបង្គំជាខ្ញុំក្នុងគ្រាឥឡូវនេះ, ហើយក៏ពោលជាបទព្រះគាថាថា:

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគញ្ឆឹ អឌ្ឍសរិំ មេ ទេហិ យាចិតោ

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ, ធម្មតាស្ទឹងទន្លេមេជលធារដ៏ពេញប្រៀបដោយឧទកវារី ជាទីពឹងប្រស្រ័យនៃមនុស្សម្នាមហាជនទាំងសត្វផងនានា ទោះបីសត្វផងជនផងផ្ទួតជន់ផឹកឥតឈប់ឈរយ៉ាងណា ក៏ពុំដែលស្រកស្រុតរីងស្ងួតអស់ទៅឡើយ ដូចម្ដេចមិញ, ឯព្រះរាជហឫទ័យរបស់ព្រះអង្គវិញក៏សឹងតែដូច្នោះ ទោះបីមនុស្សកំសត់ទុរគតទីទាល់ក្រមកសូមរបស់អ្វី ក៏ព្រះបក្រីពុំដែលខ្វះខាតឬទីសទាល់ឡើយ, ឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំមកសូមសរីរៈពាក់កណ្ដាល សូមព្រះករុណាទ្រង់ព្រះមេត្តាប្រោសព្រះរាជទានដល់ទូលព្រះបង្គំជាខ្ញុំកុំខាន ។

ព្រះមហាសត្វទ្រង់ព្រះសវនាការនូវពាក្យនោះហើយក៏មានព្រះទ័យប្រកបដោយបីតិ មានសេចក្ដីសំគាល់ថា ហាក់ដូចជានឹងបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោកក្នុងថ្ងៃស្អែក ទើបទ្រង់ត្រាស់ថា "ម្នាលមហាព្រាហ្មណ៍អើយ ប្រពៃហើយ ស្រួលហើយ, យើងនឹងបំពេញសេចក្ដី

ប្រាថ្នាកន្ទិចត្តរបស់អ្នកឲ្យបានសព្វគ្រប់ ហើយទ្រង់មានព្រះរាជហឫទ័យ មិនជាប់ជំពាក់ មិនរើរេក់យ រីករាយដូចជាបុរសកំសត់ដែលកំពុងលា ដៃស្រាប់ ហើយគេយកថង់ដែលពេញដោយពាន់នៃកហាបណៈមកដាក់ លើដៃនោះ ទើបទ្រង់ត្រាស់ថា:

ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ ន បដិគុយ្ហាមិ ទានេ មេ រមតី មនោ
បក្កុំ សីសញ្ច ហទយំ ជីវិតំ មេ សលោហិតំ
ទទាមិ ន វិកម្បាមិ ពោធិយា យេវ ការណាតិ

ម្នាលព្រាហ្មណ៍អ្នកសុំរបស់ណា យើងឲ្យរបស់នោះ ឥតមានរួញរាទ្បើយ យើងមិនលាក់ទុករបស់ដែលមានទេ ចិត្តយើងត្រេកអរតែក្នុងការឲ្យទាន យើងនឹងឲ្យភ្នែក ឲ្យក្បាល ឲ្យបេះដូង ឲ្យជីវិត ឲ្យសាច់ ឲ្យឈាម ឥតមានរួញរាទ្បើយ ព្រោះហេតុចង់បានត្រាស់ពោធិញ្ញាណតែម្យ៉ាង ។

តពីនោះមកទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍! ចូរអ្នករង់ចាំក្នុងទីនេះសិនចុះ" ហើយទ្រង់ឡើងទៅលើប្រាសាទ ទ្រង់ប្រជុំពួកអ្នកនគរមានអាមាត្យជាដើម ទ្រង់មានព្រះរាជឱង្ការត្រាស់ឲ្យហៅនាងបទុមវតីទេវី ឲ្យហៅចន្ទកុមារ ជាបុត្ររបស់ព្រះអគ្គមក ហើយទ្រង់ឧបរិតបោស

អន្ទែលប្រាប់ថា "ម្នាលកូន ជាទីស្រឡាញ់ពេញចិត្តមាសអាពុកអើយ. តាំងពីថ្ងៃនេះទៅហើយ ចូរអ្នកកុំប្រហែស ចូរអ្នកឲ្យទាន រក្សាសីល បំរើនភាវនាកុំខាន; បានជាបិតាប្រាប់ដូច្នេះ ព្រោះបិតានឹងឲ្យអជ្ឈត្តិកទាន ក្នុងថ្ងៃនេះឯង" ហើយទ្រង់ឲ្យព្រះរាជបុត្រគង់លើរតនបល្ល័ង្កទ្រង់ស្រោចអភិសេកឧទកធារា ដោយកុណ្ឌីរមាស ប្រគល់រាជ្យដល់ព្រះរាជបុត្រនោះ ។ លំដាប់ពីនោះមក ព្រះរាជាទ្រង់ស្តេចទៅកាន់សំណាក់ព្រាហ្មណ៍ដែលមកសូមទាន ទ្រង់មានព្រះរាជឱង្ការថា "ម្នាលមហាព្រាហ្មណ៍អើយ! អ្នកកុំគិតឡើយ យើងនឹងបំពេញបំណងក្នុងចិត្តរបស់អ្នក ឲ្យពេញបរិបូណ៌ឥតទើសទាល់" ។ ព្រាហ្មណ៍នោះក្រាបបង្គំទូលថា "បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ, សូមព្រះអង្គទ្រង់ព្រះរាជទានសរីរៈពាក់កណ្តាលដល់ទូលព្រះបង្គំជាខ្ញុំឆាប់ៗ" ។ ព្រះរាជាមានព្រះរាជឱង្ការថា "ម្នាលមហាព្រាហ្មណ៍ ប្រពៃហើយ ល្អហើយ" រួចមានព្រះប្រាថ្នានឹងប្រកាសដល់ពួកទេវតា ទើបទ្រង់ទតទៅឯអាកាសទ្រង់ត្រាស់យ៉ាងនេះថា:

សុណន្តុ ភោន្តោ វចនំ ទេវសង្ឃា សមាគតា
ជហាមិ ជីវិតំ មយ្ហំ ពោធិយា យេវ ការណាតិ

បពិត្រទេវតាទាំងឡាយដ៏ចំរើនអើយ, សូមអ្នកទាំងឡាយអញ្ជើញមកជួបជុំចាំស្តាប់ពាក្យខ្ញុំ ដ្បិតខ្ញុំលះបង់ជីវិតរបស់ខ្ញុំ ដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងលោក ក្នុងកាលជាអនាគត ។

លំដាប់ពីនោះមក ទ្រង់អធិដ្ឋានថា "គោនោះ បពិត្រទេវតាទាំង ឡាយដ៏ចំរើនហើយ ! សូមអ្នកទាំងឡាយចាំស្តាប់ពាក្យខ្ញុំៈ ព្រះពោធិសត្វ ទាំងឡាយអំពីបុរាណ ដែលបានដល់នូវសព្វញ្ញុតញ្ញាណ ពិតជាបាន ដោយការបរិច្ចាគ ៥ យ៉ាង; ដោយពាក្យសច្ចនេះ សូមឲ្យរណារធ្លាក់ ចុះមកឆាប់ៗកុំខាន" ។

តស្មិំ សមយេ សម័យនោះមានយក្សពីរ មានធ្មេញក្រហម មានភ្នែកក្រហម មានរោមក្រហម មានចិញ្ចើម ពុកមាត់ ពុកចង្កាទាំង សក់ក្រហម មានចង្កូមដូចជាក្រចកជ្រូកយ៉ាងធំ មានរូបគួរស្បើមក្រៃពេក មានដៃកាន់រណារ ទម្លាយផែនមហាប្រឹថពីមក ដោយកម្លាំងនៃ សេចក្តីអធិដ្ឋានរបស់ព្រះពោធិសត្វ ។ មនុស្សទាំងឡាយឃើញយក្ស ទាំងនោះហើយ ក៏ភិតភ័យតក់ស្លុតរត់រស់ ៗ គ្រានោះ ព្រះរាជា ទត ព្រះនេត្រឃើញយក្សទាំងពីរហើយ ទ្រង់មានព្រះរាជឱង្ការថា "ម្នាល មហាយក្ស ! ប្រពៃហើយ ! ស្រួលហើយ ! ចូរអ្នកអនុមោទនាអជ្ឈត្តិ- កទានរបស់យើង ដោយសេចក្តីអនុគ្រោះចំពោះយើង, ព្រោះយើងចង់ ឲ្យសរីរៈពាក់កណ្តាលដល់ព្រាហ្មណ៍ ចូរអ្នកអារពន្លះខ្លួនយើងតាំងពី ក្បាលរហូតដល់ចុងជើង យើងនឹងឲ្យខ្លួនមួយចំហៀងដល់ព្រាហ្មណ៍, មួយចំហៀងទៀតចូរអ្នកបរិភោគចុះ" ។

គ្រានោះ យក្សទាំងពីរក៏ទទួលព្រមថា "សាធុ មហារាជ, បពិត្រមហារាជ! ប្រពៃហើយ! ល្អហើយ ៗ" រួចក៏ដើរចូលទៅកាន់សំណាក់ព្រះពោធិសត្វ ឋិតនៅក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះពោធិសត្វចាប់យករណារហើយបោសអង្គែលរណារនោះដោយព្រះហស្ត ចង់ញុំាងពួកទេវតាឲ្យជ្រាប; ទើបទ្រង់ងើបមើលអាកាសហើយត្រាស់យ៉ាងនេះថា "បពិត្រពពួកទេវតាទាំងឡាយដ៏ចំរើនអើយ! ដោយការបរិច្ចាគនូវខ្លួនរបស់ខ្ញុំនេះ ខ្ញុំមិនប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រះព្រហ្ម សម្បត្តិស្តេចចក្រពត្តិ សម្បត្តិព្រះបច្ចេកពុទ្ធ សម្បត្តិសាវ័កឡើយ; សូមឲ្យបានជាបច្ច័យនៃការត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ! កាលបើខ្ញុំបានសម្រេចនូវសព្វញ្ញុតញ្ញាណហើយ នឹងបានដោះនូវសត្វលោកព្រមទាំងទេវតាឲ្យរួចចាកសំសារវដ្ត" ។ គ្រានោះ ពួកទេវតាក៏ក្កុកក្កឹកគឹកកងឡើងទាំងពួកមហាជនមានអាមាត្យជាប្រធាន ក៏មានអាការញាប់ញ័រពេញទាំងផ្ទៃផែនដី គក់ទ្រូងរំសាយសក់ទ្រហោយំ ព្រួសូរទ្រហឹងអឺងកងរំពងទាំងព្រះរាជវាំង ។ លំដាប់នោះ យក្សទាំងពីរក៏អារពន្ធះព្រះសិរព្រះពោធិសត្វ ។ ដំណឹងនោះ ក៏ជ្រាបដល់ព្រះនាងបទុមវតីទេវី ព្រះនាងទ្រង់ចុះចាកប្រាសាទ រត់មករំសាយសក់ ដំព្រះទ្រូង នេត្រាក៏ជោកជាំដោយជលនេត្រា មកក្រាបទៀបព្រះបាទព្រះពោធិសត្វ ខបរិតហើយទ្រង់ព្រះកន្សែងថ្ងូងពិលាបអាណិតអាសូរក្រពេក ។ ទាំងបន្ទុកមារ

ក៏ស្ដេចមកឧបរិតព្រះបាទាទ្រង់ព្រះកន្សែងសោកជាមួយព្រះវររាជមាតា ។ កាលបើយក្សអារព្រះពោធិសត្វដល់ព្រះនលាដៈហើយ ឈាមក៏ហូរចេញមក ។ សម័យនោះឯង ទេវតាទាំងឡាយប្រជុំគ្នាលើកឡើងនូវទង់ជាយទង់ជ្រុងសំពោងព្រោងព្រាត ទូងភេរីឲ្យពរសព្ទសាធុការ ។ ភ្លៀងជាវិការនៃផ្កាគ្រប់យ៉ាង ក៏បង្អុរចុះមក ។ មហាមេឃពុំដូកាល ក៏បណ្ដាលឲ្យមានផ្គរបន្ទោររន្ទះពាសពេញទាំងអាកាស ។ អាកាស-ទេវតាទាំងឡាយ ក៏បូជាដោយទៀនធូបប្រទីបភ្ញីផ្កាផ្សេង ៗ ហើយឲ្យសព្ទសាធុការពរ ដល់ព្រះពោធិសត្វ ។ កាលបើយក្សអារពីត្រឹមព្រះនលាដៈ មកដល់ព្រះឧរ ព្រះមហាសត្វទ្រង់ត្រាស់ព្រះរាជឧង្ការបំពោះមហាជនទាំងឡាយយ៉ាងនេះថា "អ្នកទាំងឡាយចូរកុំសោកខ្សឹកខ្សួលឡើយ" ។ ស្រីស្នំទាំងឡាយ មាននាងបទុមវតីជាប្រមុខ នាំគ្នាមកក្រាបទៀបព្រះបាទព្រះរាជាហើយសោកបោកកាយពល់ ៗ គ្នា ។ គ្រានោះ ព្រះពោធិសត្វ ដែលយក្សអារដល់ព្រះសុរង់ហើយទ្រង់ក៏រងទុក្ខ-វេទនាដ៏ក្លាខ្លាំង កាន់តាំងព្រះស្មារតី ទើបព្រះចក្រីមានព្រះរាជឧង្ការថា ព្រះបាទសិរីបុញ្ញាមណី ជាសម្មាសម្ពុទ្ធបានឃើញនូវពួកសត្វដល់ហើយនូវសេចក្ដីទុក្ខ ក៏ខំប្រឹងព្យាយាមធ្វើអំពើដែលអ្នកដទៃធ្វើបានដោយកម្រព្រោះតែសេចក្ដីអាណិតអាសូរប៉ុណ្ណោះ ។ លំដាប់នោះ យក្សទាំងពីរអារបំបែកសរីរៈរបស់ព្រះអង្គ ដោយរណារមាស រហូតដល់បេះដូង;

ទុក្ខវេទនា ក៏រឹងរឹតតែចំរើនច្រើនឡើង ទើបទ្រង់មានព្រះរាជឱង្ការប្រាប់យក្សថា "ម្នាលយក្ស! ចូរអ្នកការបំបែកសរីរៈយើងឲ្យស្រួល" ។ គ្រានោះឈាមក៏ហូរចេញស្រោចពេញសរីរៈរបស់ព្រះអង្គទាំងអស់ ស្រក់ដេរដាសពាសពេញទាំងមហាប្រឹថពី ។ យក្សក៏ការពុះសរីរៈពីត្រឹមពោះរហូតដល់ចំណែកខាងក្រោម ។ គ្រានោះឯង ពួកស្រីស្នំមានព្រះនាងបទុមវតីទេវីជាប្រធាន ព្រមទាំងចន្ទកុមារជាព្រះរាជបុត្រ ទាំងបុរោហិត និងពួកសេវកាមាត្យព្រមទាំងពពួកមហាជន ក៏ដេកដួលសន្លប់បាត់ស្មារតីលើមហាប្រឹថពី ។ ឯព្រះរាជាទ្រង់ទតព្រះនេត្រទៅឃើញសរីរៈតែមួយចំហៀងដូច្នោះហើយ ក៏ទ្រង់ព្រះរាជទានសរីរៈមួយចំហៀងនោះដល់ព្រាហ្មណ៍ ហើយត្រាស់ថា "ម្នាលព្រាហ្មណ៍! ទានរបស់យើងនេះសូមឲ្យបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណ" ។ ព្រាហ្មណ៍ក៏កាន់យកសរីរៈមួយចំហៀងនោះទៅចងផ្តាប់នឹងសរីរៈរបស់ខ្លួន ។ ពួកទេវតាទាំងឡាយមានព្រះព្រហ្មជាដើម ក៏ថ្វាយសព្ទសាធុការពរចំពោះព្រះពោធិសត្វគងរំពង ។ ទេវតាទាំងឡាយ ក៏ទូងកើឲ្យពរសព្ទសាធុការ ។ ភ្លៀងក៏ធ្លាក់គ្រប់បែប ក៏បង្អុរចុះមកថ្វាយ ។ ពួកមហាជនទាំងឡាយក៏ក្កុកក្កឹកកងឡើង ។ សក្កទេវរាជ ក៏ធ្វើសរីរៈរបស់ព្រះពោធិសត្វឲ្យពេញលេញឡើងដូចប្រក្រតីវិញ ល្អដូចជារូបមាសតាន់ ។ ព្រះពោធិសត្វ កាលបើមានសរីរៈពេញលេញល្អដូចជារូបមាសហើយ ទ្រង់

ក្រោកឡើងគង់នៅក្នុងទីនោះឯង ៗ គ្រានោះ សក្កទេវរាជ បានជ្រាប អធ្យាស្រ័យដ៏ប្រសើរ របស់ព្រះពោធិសត្វនោះហើយ ក៏ពោលសរសើរ ព្រះពោធិសត្វជាអនេកប្រការ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលសម្តេចព្រះបរម-សពេជ្ញសាស្តា បានត្រាស់ឡើងហើយ ទ្រង់ប្រកាសសេចក្តីនោះថា:

តស្ស សង្កប្បមញ្ញាយ ទេវិន្ទោ ឯតទព្រវិ
សព្វេ ជិតា តេ បច្ចូហា យេ ទិព្វា យេ ច មានុសា
និន្នាទិតា តេ បថវី សទ្ទោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគូ គិរីនំ វ បតិស្សុតា
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ព្រហ្មា បជាបតី សោមោ យមោ វេស្សវណោ
សព្វេ ទេវា អនុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្វយោ
តស្មា សតញ្ច អសតំ នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ នេន្តិ សន្តោ សគ្គបរាយណា

សក្កទេវរាជ ជាធំជាងទេវតា បានជ្រាបច្បាស់នូវសេចក្តីត្រិះរិះរបស់ព្រះរាជានោះហើយ ទើបពោលពាក្យដូច្នេះថាៈ ដែនទាំងមូលព្រះអង្គលះបង់ហើយ, វត្ថុទាំងឡាយឯណាជារបស់ទិព្វក្តី ជារបស់មនុស្សក្តី ក៏ព្រះអង្គលះបង់ហើយដែរ, ផែនប្រែបពីជាទីទ្រទ្រង់នូវសត្វ ព្រះអង្គធ្វើឲ្យរករើកកំពើកហើយ, សំឡេងសរសើរចំពោះព្រះអង្គ ផ្សាយទៅហើយដល់ពិភពតាវត្តិង្ស, ផ្គរបន្ទោរ ក៏លេចឡើងផ្ទៀលផ្ទាត់ជាលប្រែវត់ព័ទ្ធជុំវិញ, ក្ដូទាំងឡាយ ក៏លាន់ឮសូរស័ព្ទកងរំពងឡើង, ក្ដូនារទៈទាំងពីរ ក៏អនុមោទនាចំពោះព្រះអង្គ, ពួកទេវតាទាំងពួង គឺព្រះឥន្ទ ព្រះព្រហ្ម ព្រះបជាបតិព្រះចន្ទ ព្រះយម ព្រះវេស្សវ័ណ សុទ្ធសឹងតែអនុមោទនាថាព្រះរាជាអង្គនោះ ទ្រង់ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រណាស់; ព្រះរាជាអង្គនោះ ទ្រង់ព្រះរាជទាននូវទានដែលបុគ្គលឯទៀត ឲ្យបានដោយកម្រ ធ្វើនូវអំពើដែលបុគ្គលឯទៀតធ្វើបានដោយកម្រយ៉ាងនេះ, អសប្បុរសទាំងឡាយមិនអាចយនឹងធ្វើតាមបានឡើយ ធម៌របស់សប្បុរសគឺអសប្បុរសដឹងបានដោយកម្រ ព្រោះហេតុនោះ បានជាសប្បុរសនឹង

អសប្បុរស តែងមានដំណើរផ្សេងៗពីគ្នា គឺអសប្បុរស
ទាំងឡាយ តែងទៅកាន់នរក ពួកសប្បុរសតែង
ទៅកាន់ស្ថានសួគ ។

សក្កទេវរាជ ទ្រង់ពោលតទៅទៀតថា "បពិត្រមហារាជ ! ព្រះអង្គបានព្រះរាជទានយ៉ាងនេះហើយ ទ្រង់កុំអាលខ្ពុតនឹងការព្រះរាជទានត្រឹមតែប៉ុណ្ណោះឡើយ" ។ គ្រានោះ ព្រះពោធិសត្វកាលបើបានរស់ព្រះជន្មឡើងវិញហើយ ក៏ទ្រង់ក្រោកចាកទីនោះ, ទើបសម្តេចសក្កទេវរាជថ្វាយសព្ទសាធុការពរ ចំពោះព្រះពោធិសត្វ រួចហើយក៏លាទៅកាន់ទេវលោកវិញ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលសម្តេចព្រះបរមសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ដូច្នេះថា:

ទេវរាជជាភស្តានៃនាងសុជាតា មាននាមថាមឃវៈ ពោល
នូវពាក្យដូច្នេះរួចហើយ ក៏ធ្វើនូវសេចក្តីសរសើរចំពោះព្រះ
ពោធិសត្វហើយចៀសចេញទៅកាន់ទេវនិកាយវិញទៅ ។

លំដាប់នោះ ពួកមន្ត្រីទាំងឡាយ មានអាមាត្យជាដើម នឹងស្តេចសាមន្តរាជ ព្រមទាំងបណ្តាជនទាំងឡាយ មានគហបតីជាដើម ក៏បានដកដង្ហើមធូរស្រួល ហើយអង្គុយប្រជុំគ្នាឲ្យសព្ទសាធុការពរចំពោះព្រះអង្គ ។ ឯព្រះពោធិសត្វ តែងទ្រង់ព្រះរាជទានជាប់ជានិច្ច

ដរាបដល់ទ្រង់ព្រះជរា ទ្រង់ក៏ប្រគល់រាជសម្បត្តិឲ្យព្រះរាជបុត្រ, រួចទ្រង់ស្តេចចេញចាកនគរ ចូលទៅកាន់ព្រៃ ទ្រង់ព្រះផ្នួសជាឥសី ញុំាងឈានឲ្យកើតឡើង លុះដល់អស់ព្រះជន្មាយុ ក៏បានទៅសោយព្រះ-ជាតិក្នុងព្រហ្មលោក ។

អង្គសម្តេចព្រះបរមសាស្តា ទ្រង់នាំព្រះធម៌ទេសនាមកសំដែងដូច្នេះ ហើយ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ! តថាគតឲ្យទាននេះមិនមែនតែក្នុងកាលឥឡូវនេះទេ កាលពីដើម ក៏ធ្លាប់តែឲ្យដូច្នេះដែរ” ។ ទើបទ្រង់ប្រជុំជាតកថា “នាងបទុមវតីទេវី ក្នុងកាលនោះគឺនាងយសោធរា ជាមាតារាហុលក្នុងកាលឥឡូវនេះ; បទុមកុមារក្នុងកាលនោះ គឺរាហុលក្នុងកាលឥឡូវនេះ; ពួកជនដ៏សេស គឺជាពុទ្ធបរិស័ទ, ព្រះបាទសិរីបុញ្ញាមណី គឺអង្គតថាគតហ្នឹងឯង” ។

អ្នកទាំងឡាយជាពុទ្ធបរិស័ទ ចូរចងចាំនូវជាតកដូចរឿងដែលថ្លែងមកយ៉ាងនេះឯង ។

ចប់សិរីបុញ្ញាមណិជាតកទី ៣ តែប៉ុណ្ណេះ

# រឿងសៅរ៍សោបេ

(សិតេករជាតក)

## ព្រះមហាឧត្តមវិជ្ជា ធិបញ្ញាណោ ប៊ឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្រ្តាស្លឹករឹត

---

| | | |
|---|---|---|
| អហំវន្ទេ | លើកម្រាមក្រពុំ | បង្គំត្រេកត្រង់ |
| ឆ្ពោះទៅព្រះពុទ្ធ | ព្រះធម៌ព្រះសង្ឃ | ទាំង ៣ នេះទ្រង់ |
| ជាម្ចាស់សិរសា ។ | ខ្ញុំថ្វាយបង្គំ | វន្ទាប្រណម្យ |
| ដោយចិត្តសទ្ធា | សរសើរសម្តេច | សពេជ្ញកគព |
| ព្រះអង្គជាតិជា | គ្រូគ្រប់កពត្រៃ ។ | ព្រះអង្គទេសនា |
| ទូន្មានទេវតា | មនុស្សសត្វទទៃ | អោះសត្វលិចលង់ |
| ការផុងទៅញ | នរកប្រេតវិស័យ | ព្រះអង្គតែងប្រោស ។ |
| ព្រះមានមេត្តា | ព្រះមានករុណា | មិនដែលយកទោស |
| មានតែផ្គត់ផ្គង់ | ស្រោចស្រង់សន្តោស | ទេសនាប្រោះប្រោស |
| សព្វសត្វទាំងឡាយ ។ | បង្គំព្រះធម៌ | មានអត្ថបវរ |
| ជ្រៅឆ្ងាយទូលាយ | តែងនាំចម្លង | សត្វផងគ្រប់កាយ |
| ទៅដាក់ត្រើយនាយ | គោលគឺនិព្វាន ។ | បង្គំព្រះសង្ឃ |
| ប្រសើរសឹងទ្រង់ | សីលសុទ្ធជាយាន | ទាំងជាស្រែបុណ្យ |

ព្រះគុណមែនមាន អាចឲ្យសត្វបាន រំលាយបាបបង់ ៗ
ហេតុនោះខ្ញុំថ្វាយ អស់អង្គកាយ ចំពោះទៅត្រង់
ព្រះរតនត្រ័យ ទាំង ៣ ព្រះអង្គ គោរពផ្ចិតផ្ចង់
ដោយចិត្តសទ្ធា ៗ ខ្ញុំបង្គំសព្វ ទូទាំងពិភព
សោឡសសួគ៌ា សូមសុខសួស្តី បុទ្ធីចេស្តា
ចំរើនទីឃា- យុយឺនកន្ទង ៗ ខ្ញុំនឹងតែងកាព្យ
ទៅតាមសភាព ដោយនូវគន្ទង សូមអស់ទេវតា
ឲ្យសាធុផង កុំឲ្យមានហ្មង ជិតដល់អង្គកាយ ៗ
សូមបុណ្យបារមី រតនៈទាំង ៣ ផ្តល់សុខសព្វសាយ
សូមតេជតបះ ពីព្រះកច្ចាយន៍ សូមសុខពណ្ណភយ
ពីព្រះបវេក ៗ សូមបុណ្យបារមី ពីព្រះជិនស្រី
ច្រើនក្រៃអនេក ដែលនិព្វានទៅ ស្ថិតនៅវិវេក
គង់ក្នុងឋានឯក ពោលគឺនិព្វាន ៗ បង្គំទៀតទៅ
ដល់ព្រះដែលនៅ ពុំទាន់ទ្រង់ញាណ ទើបសាងបារមី
នៅទីសល់ខាន ត្រាស់ក្រោយប៉ុន្មាន បង្គំទាំងអស់ ៗ
ទូទាំងឥន្ទព្រហ្ម ស្ថិតស្ថានឧត្តម សុខសួគ៌សោឡស
សព្វព្រៃព្រឹក្សា បព្វតាទាបខ្ពស់ ស្ទឹងបឹងទាំងអស់
សព្វជ្រោះធារ ៗ សូមជាប្រធាន សាក្សីពេជ្ញញាណ

នៃអញខ្ញុំណា ខ្ញុំតាំងផ្គងចិត្ត ហើយចេញវាចា
សូមសាងប្រាថ្នា ប្រាថ្នាទៅមុខ ៗ កើតជាតិណា ៗ
ត្រង់ព្យាធិរោគា អំពល់ជាទុក្ខ នោះកុំឲ្យមាន ។
ឲ្យបានតែសុខ សព្វជាតិទៅមុខ ទុក្ខកុំឲ្យស្គាល់ ៗ
សូមឲ្យបានចេះ របៀនចំណេះ ត្រៃបិដកធម៌
ចេះចាំប្រាកដ រត់មាត់ឥតសល់ កុំឲ្យទើសទាល់
ដល់តិចឡើយណា ៗ ជាតិនេះអញខ្ញុំ អភ័ព្វពេកពុំ
ទាន់ព្រះសាស្តា កើតទាន់ប្រទះ តែព្រះសាសនា
កើតជាតិបរ (១) ឲ្យបានទាន់ព្រះ ៗ ខ្ញុំសូមប្រាថ្នា
ព្រះត្រាស់កាលណា ឲ្យបានប្រទះ ឲ្យបានថ្វាយថ្វាត់
ប្រតិបត្តិគុណព្រះ ឲ្យខ្ញុំបានឈ្នះ អំពើអកុសល ៗ
ឲ្យអស់ទេវតា ឥន្ទ្រព្រហ្មក្តីណា ជួយជាកំណល់
កសិណសាក្សី កុំបីមានឆ្ងល់ ប្រាថ្នាបានដល់
អគ្គសាវ័កស្តាំ ៗ ទាំងនាងគង្ហីង- ធរណីនោះឯង
ចូរជួយចងចាំ ពាក្យប្រណិធាន ដែលបានតាំងមាំ
ទុកជាចំណាំ កុំភ្លេចឡើយណា ៗ ឥឡូវនេះខ្ញុំ
សូមលើកសេចក្តី ពីព្រះសាស្តា កើតតាមទំនង

---
១ ជាតិមុខ ។

ល្បោចល្បងប្រាជ្ញា ជាបទកាព្យ ពាក្យពេចន៍បរិយាយ ៗ
ទោះបីលើសលោះ ខុសខកខ្វកខ្វោះ បទបាទទាំងឡាយ
ទាំងពាក្យសំដី សេចក្តីសម្ដាយ សូមលោកទាំងឡាយ
សន្តោសទោសា ៗ ខ្ញុំនឹងអធិប្បាយ ពាក្យពេចន៍បរិយាយ
ពីព្រះសាស្តា កាលសោយព្រះជាតិ ជាស្តេចនាមា
សិវិរាជា រង់ទុក្ខពេកក្រៃ ៗ បើអ្នកឯណា
មិនមានប្រាជ្ញា សូមជួយតម្រែ តម្រង់ឲ្យបាន
ឲ្យបានត្រឹមត្រូវ ដ្បិតខ្ញុំនេះក្រៃ ពុំសូវប្រាជ្ញប្រាយ ៗ
អហំរីខ្ញុំ លើកដៃឡើងផ្គុំ ប្រណម្យថ្វាត់ថ្វាយ
នឹងលើកជាកាព្យ កំណាព្យទាំងឡាយ ពាក្យពេចន៍បរិយាយ
រឿងព្រះកគក់ ៗ ព្រះអង្គបានត្រាស់ ជាព្រះពុទ្ធច្បាស់
ផ្ចាញ់ក្រុងមារ បាក់បបខូចខាច អំណាចចេស្តា
ព្រះតែងទេសនា ទូន្មានសព្វសត្វ ៗ ខ្លះបានសោតា
ខ្លះបានសកិទា ខ្លះបានអរហត្ត ព្រះអង្គតែងប្រោស
សន្តោសសព្វសត្វ ទូន្មានកំចាត់ ពីសង្សារ ៗ
ព្រះជន្មស្តេចបាន បរិបូណ៌មិនមាន ប៉ែតសិបវស្សា
កាលណោះព្រះអង្គ ទ្រង់គង់នៅនា ជេតពនមហា
ទៀបសាវត្ថី ៗ ព្រះអង្គទេសនា អំពីកម្មា

នៃព្រះអង្គទ្មី ដែលអ្នកប្រាជ្ញផង បានចងសេចក្តី
ទុកក្នុងបាលី តាមរឿងនិទាន ។ សេចក្តីនោះថា
កាលព្រះសាស្តា ជិតចូលនិព្វាន ពេលនោះឯងហោង
ភិក្ខុផងសព្វថាន ជ្រួលជ្រើមគ្រប់ប្រាណ ជំនុំគ្នាថា ។
អាវុសោទាំងឡាយ ! ចូរលោកមៀងហ្មាយ មើលផលកម្ម
អម្បាលសម្តេច សពេជ្ញកគរ ជាម្ចាស់សិរសា
នៃយើងទាំងឡាយ ។ ព្រះអង្គខ្ពង់ខ្ពស់ ប្រសើរលើសអស់
មនុស្សសត្វសម្ងាយ គង់តែផលកម្ម ប្រចាំព្រេងនាយ
ជិតជាមតាមកាយ ឲ្យទុក្ខសែនទ្វី ។ គឺកាលព្រះអង្គ
ទ្រង់មានចំណង់ ចង់សោយវារី ទឹកថ្លាក្នុងស្ទឹង
កុកជនទី ទឹកនោះប្រែពី ថ្លាស្អាតថ្លៃថ្លា ។
ទៅជាទឹកល្អក់ ជាទឹកក្រខ្វក់ គួរអ្វីច្នេះណា
បាច់ពោលទៅថ្វី ដល់សព្វសត្តា អម្បាលសាស្តា
គង់សោយផលកម្ម ។ ទើបព្រះកគរ សំដែងទេសនា
តាមដោយចំណាំ ប្រាប់សង្ឃគ្រប់គ្នា ទុកជាបណ្តាំ
ភិក្ខុអើយកម្ម អង្គអញនេះណា ។ មិនតែឥឡូវ
កម្មនោះឯងគួរ កាលអញតថា- គតយកកំណើត
កើតជាក្សត្រា ធ្វើឲ្យអាត្មា ព្រាត់ប្រាសស្ទើរក្ស័យ ។

អត់បាយឥតបើ  បានតែផ្លែឈើ  គ្រាន់នឹងអាស្រ័យ
វេទ្ទនាម្នាក់ឯង  កណ្ដាលកណ្ដាលព្រៃ  លំបាកពេកក្រៃ
ឥតឯគណនា ៗ  បន្ទូលម៉្លោះហើយ  គង់ស្ងៀមកន្ដើយ
ពុំមានពុទ្ធដីកា  ទើបអស់ភិក្ខុផង  ផ្គងវន្ទា
អាពាធនា  ព្រះធម៌ព្រះអង្គ ៗ  ទើបព្រះនរនាថ
ទទួលអាពា-  ធនាអស់សង្ឃ  ស្រេចហើយថាថ្លែង
សំដែងត្រាស់ទ្រង់  ប្រាប់ភិក្ខុសង្ឃ  ពីកម្មដំបូក ៗ
ថាភិក្ខុទាំងឡាយ !  ចូរលោកខ្វល់ខ្វាយ  ស្ដាប់អង្គអញញែក
ថាកាលពីព្រេង  អន្លើងលន្លើក  យូរជាអនេក
កន្ទង់ឆ្ងាយទៅ ៗ  ភិក្ខុអើយកាលនោះ  មានក្សត្រ ១ ឈ្មោះ
ព្រះបាទសិសៅរ៍  សោយរាជ្យទសពិធ  ថេរបិតនិត្យនៅ
នគរឈ្មោះហៅ  អនន្ដនគរ ៗ  រីអគ្គមហេសី
ល្អល្អះប្រិមប្រិយ  ប្រុសស្រីសាទរ  នាមអនន្ដា
ទេវីបវរ  ជាឆ្នើមនគរ  លើសលែងស្រីផង ៗ
ស្ដេចមានស្រីស្នំ  ល្អ ៗ សក្ដិសម  ៦ ហ្មឺនហោង
ថ្វាយ ៦ ពាន់  ណាស់ណានគន្ធង  បំរើច្បាស់ច្បង
នោះជាប្រក្រតី ៗ  នាងខ្វះបក់ផាត់  ចោមជុំមហាក្សត្រ
ខ្វះថ្វាយព្រះស្រី  ខ្វះកាន់ព្រះពស្ដ្រ  ថ្មីស្រស់ឥតបី

នាងខ្ទះឃ្មាតខ្មី គក់ប្រដាប់ផង ៗ បំរើសព្វថ្ងៃ
ផ្គាប់ព្រះហឫទ័យ មិនឲ្យមានហ្មង ស្ដែងស្ដេចជាធំ
ថ្កើងថ្កុំកន្លង អស់ពស្ត្រាសផង សាន្ដសុខសប្បាយ ៗ
កបកើតសម្បត្តិ សម្បូរ៌ច្រើនក្ដាត់ ឧឡារិកឆ្ងាយ
មានមុខមន្ត្រី សេនីយទាំងឡាយ ព្រាហ្មណ៍ព្រឹទ្ធប្រាជ្ញប្រាយ
ហ្មបហ្មាយជិតជុំ ៗ អស់ទាំងពួកឈ្មួញ ដែលធ្វើជំនួញ
មូលមកកុះកុំ ចេញជួញទៅមក ដោយពួកដោយក្រុម
កុញកកកុះកុំ ច្រើនក្រៃត្រៀបត្រា ៗ មានទាំងចតុរង្គ
ប្រដាប់គ្រប់អង្គ លំពែងធ្នូស្នា ឥតមានក្លាំងក្លឹក
ទឹងសឹកឯណា សឹងតែហានក្លា ទីទៃគ្រប់ប្រាណ ៗ
មានឃ្លាំងមាសប្រាក់ អនេកអនគ្ឃ ច្រើនពន់ប្រមាណ
សព្វស្ដេចនានា ឧបមាពុំបាន ឮល្បីថ្កើងថ្កាន
ទូទិសនានា ៗ ថ្កើងកេរ្ដិ៍ថ្កើងយស ថ្កើងវង្សខ្ពង់ខ្ពស់
ប្រៀបផ្ទឹមឧបមា ស្មើនឹងមហាចក្រ ឫទ្ធិសក្ដិថ្លៃថ្លា
អស់ស្ដេចនៅនា ជម្ពូទ្វីបនោះ ៗ សឹងតែគោរពខ្លាច
ដោយនូវអំណាច នាំគ្នាមកឆ្ពោះ ថ្វាត់ថ្វាយសួយរ៉ៃ
សព្វថ្ងៃគ្មានលោះ ផ្សេងៗដោយឈ្មោះ កែវកងមាសប្រាក់ ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ១៨

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

តាំងស៊ុននៅមិនទាន់ទុកចិត្តជាប្រាកដ ក៏ធ្វើជាតក់ស្លុតហើយនិយាយនឹងម៉ាចេងថា ហេតុអ្វីបានជាអ្នកយកសេចក្ដីនេះមកប្រាប់ សព្វថ្ងៃនេះបុច្ចជាទីមហាចក្រពត្រសម្រេចរាជការផែនដី ដែលអ្នកមកប្រាប់ដូច្នេះ បើមានគេដឹងនឹងនាំសេចក្ដីទៅជំរាបបុច្ច យើងនឹងមិននាំគ្នាស្លាប់អស់ទេឬ? ។ ម៉ាចេងថា អ្នកនៅរាប់អានបុច្ចថាជាមនុស្សល្អ តែអ្នកជាមនុស្សប្រែចុបប្រែចែងស្រឡាញ់ជីវិត មិនមែនមានចិត្តនឹងជួយទំនុកបំរុងផែនដីឲ្យបានសេចក្ដីសុខ ចូរអ្នកនៅឲ្យសប្បាយចុះ ខ្ញុំលាទៅហើយ ។ តាំងស៊ុនឃើញថា ម៉ាចេងសំដែងខ្លួនទៀងត្រង់ប្រាកដនឹងព្រះចៅ-

ហៀនគេដូច្នោះក៏និយាយថា "អ្នកកុំភាលខឹងសំបា សុំឲ្យឈប់ស្ដាប់ខ្ញុំនឹងនិយាយឲ្យស្ដាប់សិន" ហើយក៏យកឡាយព្រះហស្ដមកឲ្យម៉ាថេងមើល ។ ម៉ាថេងស្គាល់ច្បាស់ថាឡាយព្រះហស្ដដូច្នោះក៏ខឹងណាស់ ទន្ទ្រាំបាតាទាំងធ្មេញទាល់តែលោហិតហូរចេញពីមាត់ ហើយនិយាយនឹងតាំងស៊ុនថា អ្នកចូររិះគិតការនេះឲ្យធាប់ចុះខ្ញុំនឹងត្រឡប់វិលទៅស្រុកសែលៀងវិញ ដើម្បីនឹងលើកទាហានមកជួយកំចាត់សត្រូវរកជសម្បត្តិចេញឲ្យបាន ។ តាំងស៊ុនក៏ហៅមន្ត្រីទាំង ៤ នាក់ឲ្យចេញមកជួបនឹងម៉ាថេង ហើយធ្វើសត្យបដិញ្ញាស្បថស្បាន់ចុះឈ្មោះជាមួយគ្នាទាំង ៦ នាក់ ។ តាំងស៊ុននិយាយនឹងម៉ាថេងថា ការដែលនឹងទំនុកបំរុងផែនដីក្នុងសម័យនេះ បើនឹងសម្រេចដូចប្រាថ្នាក៏ដោយសារជំរេះរបស់អ្នក ។

ដូហុក, ដូឡាន់, តាន់អ៊ុប, ង៉ោហួននិយាយគ្នាថា យើងនឹងគិតប្រការម្ដេច ទើបនឹងបានមនុស្សទៀងត្រង់នឹងផែនដីមកជួយរិះគិតទៀត? ។ តាំងស៊ុនឆ្លើយថា ការគ្រានេះជាទីកំបាំង បើយើងនឹងនិយាយឲ្យបែកការក៏នឹងឲ្យខូចខ្ទេចអសារ ។ ម៉ាថេងបានឮមន្ត្រី ៤ នាក់នឹងតាំងស៊ុននិយាយគ្នាដូច្នោះ ក៏នឹកគិតឡើងឃើញឡៅពី ១ ទៀត ហើយទះដៃអស់សំណើចថា យើងបានម្នាក់ទៀតហើយ ។ តាំងស៊ុនសួរថា អ្នកឯណា? ។ ម៉ាថេងថា ឡៅពីជាពូជព្រះរាជវង្សព្រះចៅហៀនតេ ហេតុម្ដេចអ្នកមិនយកមករួមគិតការនេះជាមួយផង ។ តាំង

ស៊ីនថា ទៀវពីជាពូជព្រះរាជវង្សក៏មែន តែថានៅក្នុងអំណាចចូច យើងនឹងទុកចិត្តជាប្រាកដមិនបានទេ ។ ម៉ាថេងថាកាលព្រះចៅហៀនតេស្តេចទៅប្រពាតព្រៃ នាហ៊ីនទាំងពួងចូលទៅថ្វាយបង្គំ ចូចញាក់សេះបរទៅបាំងពីមុខព្រះភក្ត្រធ្វើអាការបីដូចនឹងគំនាប់មន្ត្រីទាំងពួង គួនអ៊ូចឹងណាស់លើកដាវឡើងនឹងកាប់ចូច ទៀវពីមិចក្នែកក្រវីក្បាលឃាត់គួនអ៊ូ យើងឃើញកិរិយាទៀវពីប្រឹងនឹងប្រទូសរ៉ាយចូចដែរ តែនៅក្រែងថាតាហានដែលមានចិត្តស្រឡាញ់គោរពខ្លាចចូចនោះច្រើន ហើយទៀវពីខ្លាចដោះការបានជាឃាត់ហាមគួនអ៊ូ ហេតុនេះបួអ្នកពិគិតនិយាយការនេះនឹងទៀវពីផងចុះ ។ តាំងស៊ីនយល់ឃើញត្រូវ ម៉ាថេងនឹងមន្ត្រីទាំង ៤ នាក់គំនាប់លាតាំងស៊ីនចេញទៅ ។

លុះវេលាយប់ តាំងស៊ីនក៏យកឡាយព្រះហស្តចេញទៅរកទៀវពី ៗ ឃើញតាំងស៊ីនមករកក៏ត្រេកអរណាស់ អញ្ជើញឲ្យបរិភោគអាហារ ។ តាំងស៊ីនដកបស្នួរទៀវពីថា កាលព្រះចៅហៀនតេស្តេចទៅប្រពាតព្រៃ គួនអ៊ូលើកដៃឡើងនឹងកាប់ចូច ហេតុម្តេចបានជាលោកហាមឃាត់ ។ ទៀវពីក៏យស្មុតចិត្តឆ្លើយថា ហេតុម្តេចបានជាអ្នកដឹងការនេះ ។ តាំង-ស៊ីនថា អ្នកឯទៀតមិនបានសង្កេតក៏មិនអាចដឹង តែខ្ញុំម្នាក់ឯងបានដឹងប្រាកដ ។

ទៀវពីបានស្តាប់តាំងស៊ីននិយាយថាឃើញការនោះប្រាកដ ក៏គិតនឹងឆ្លើយបដិសេធ តែទាស់ចូលក្នុងសេចក្តីវៀច ទើបឆ្លើយតបថា គួនអ៊ូ

ឃើញមហាឧបរាជធ្វើល្មើសទ្រទុងសក្តិ នៅមុខព្រះភក្ត្រ បានជាប្អូនខ្ញុំនឹកខឹងបន្តិចទៅហើយ ។ តាំងស៊ុនឮឡៅពីថាដូច្នោះ ក៏គិតដល់ព្រះចៅហៀនតេជាម្ចាស់ផែនដីមានសេចក្តីឈឺចិត្តណាស់ ស្រក់ទឹកភ្នែកយំសោកថា ប្រសិនបើមន្ត្រីខ្ញុំរាជការទាំងឡាយ ជួយឈឺឆ្អាលស្រឡាញ់ម្ចាស់ផែនដីដូចគួនអ៊ូហើយ កាលណាឡើយព្រះចៅហៀនតេនឹងព្រួយលំបាកក្នុងព្រះទ័យដល់ម៉្លេះ ។ ឡៅពីបានឮដូច្នោះ ក៏នៅមិនទាន់អស់សេចក្តីសង្ស័យ គិតថា ប្រហែលចូចូក្លែងកលឧបាយឲ្យតាំងស៊ុនមកល្បងនិយាយទេដឹង? ទើបក្លែងពោលថា សព្វថ្ងៃនេះចូចូជាមហាឧបរាជ មានអំណាចសម្រេចរាជការជួយយកអាសាផែនដីណាស់ ហេតុម្តេចបានជាអ្នកថាសព្វថ្ងៃព្រះចៅហៀនតេទ្រង់ព្រួយព្រះរាជហឫទ័យ ខ្ញុំមិនឃើញផងសោះ ។ តាំងស៊ុនខឹងណាស់ក្រោកឡើងស្រែកថា ខ្លួនអ្នកជាធំព្រះចៅហៀនតេទ្រង់ប្រោសរាប់អានថាជាពូជព្រះរាជវង្ស ហេតុម្តេចក៏អ្នកត្រឡប់ទៅលើកកំពស់អាមនុស្សទ្រុស្តក្បត់ផែនដីទៅវិញ ឬអ្នកនិយាយជាឧបាយបញ្ឆោតចិត្តយើងទេ ។

ឡៅពីឃើញថា តាំងស៊ុនសំដែងសេចក្តីសត្យត្រង់នឹងព្រះចៅហៀនតេប្រាកដ ទើបតបថា កាលដំបូងយើងនៅសង្ស័យ ក្រែងអ្នកដើរក្នុងកលឧបាយមកបញ្ឆោតយើង បានជាយើងបរបាដូច្នោះ ។ តាំងស៊ុនក៏ហូតយកឡាយព្រះហស្តហុចឲ្យឡៅពីមើល ។ ឡៅពីឃើញជាក់ជា

ឲ្យាយព្រះហស្ដហើយ  ក៏គិតខ្លាចចិត្តអាណិតព្រះចៅហៀនគេជាអនេក យំយែកស្រក់ទឹកភ្នែក ៗ ក្នុងខណៈនោះ តាំងស៊ុនក៏ហុចសំបុត្រសញ្ញាដែលគិតធ្វើការជាមួយនឹងឈ្មោះទាំង ៦ នាក់នោះ ឲ្យឡៅពីមើលទៀត ៗ ឡៅពីតបថា ដែលអ្នករិះគិតកំចាត់ចូចូនោះ យើងនឹងសុំចូលធ្វើការផង ៗ តាំងស៊ុនថា ប្រសិនបើជាអ្នកចូលគិតទំនុកបំរុងផែនដីជាមួយនឹងយើង ក៏ឲ្យចុះនាមលេខាសញ្ញាទុកជាសំគាល់នឹងបានជួយគ្នាធ្វើការតទៅ ៗ ឡៅពីក៏ចុះនាមលេខាក្នុងសញ្ញានោះទៀតរួមជា ៧ នាក់ប្រគល់ឲ្យទៅតាំងស៊ុនហើយក៏ជាប់ថា ដែលនឹងធ្វើការគ្រានេះឲ្យអ្នកគិតត្រិះរិះឲ្យល្អ តែបែកធ្លាក់ធ្លាយទៅកាលណា ការក៏មិនសម្រេច ខ្លួនយើងទាំងអស់គ្នាក៏បានទុក្ខព្រួយជាខ្លាំង ៗ តាំងស៊ុនទទួលពាក្យឡៅពីហើយក៏លាទៅផ្ទះ ៗ (មានត)

---

**មើលសៀវភៅប្រសើរជាងមើលរបាំ**

មើលសៀវភៅ នាំឲ្យទៅ ជាអ្នកចេះ
នូវចំណេះ ទាំងផ្លូវលោក ទាំងផ្លូវធម៌
នាំឲ្យចិត្ត ប្រព្រឹត្ត កម្មបវរ
មើលរបាំ នាំឲ្យក្រ វិនាសធន ៗ

យ. អ.

# ណាលៈនឹងទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រី ស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

ពួកឆ្មាំទ្វារគិតស្មានថាមនុស្សឆ្កួត ប៉ុន្តែនាំគ្នាជំនុំថា "បើនឹងនាំការណ៍នេះទៅទូលព្រះបាទភិមៈ ព្រះបាទណាលៈនឹងព្រះនាងទមយន្តីឲ្យជ្រាបផង ទើបជាការល្អ" រួចក៏នាំគ្នាទៅក្រាបទូលព្រះបាទភិមៈសព្វគ្រប់ប្រការ ។ ព្រះបាទភិមៈលុះបានជ្រាបដំណឹងអាក្រក់នោះទ្រង់ញញឹមបែបខ្ទើមទាំងមិនជឿថាជាអាទិទេពមែនទែនទេ ព្រោះទ្រង់យល់ដូចពួកឆ្មាំទ្វារដែរ ។ ឯព្រះបាទណាលៈនឹងព្រះនាងទមយន្តីគ្មានបានជ្រាបការណ៍នេះសោះ ។

លុះដល់ពេលស្ដេចទីន យាងត្រឡប់មកកាន់ប្រទេសនិសធៈវិញ គេយកនូវរតនវត្ថុគ្រប់បែបមកចងព្រះហស្តព្រះអង្គ ព្រមទាំងថ្វាយនូវសាធុការពរជ័យមង្គលដល់ទ្រង់ ៗ ទ្រង់យាងដោយក្បួនហែជាយ៉ាងឧឡារិក ។

គេឃើញមនុស្សម្នាក់មុខមាត់អាក្រក់ដើរតាមក្រោយក្បួនហែ បុរសនោះសើចស្ដុតបណ្ដើរ ។

*
* *

ព្រះបាទនាលៈនិងព្រះនាងទមយន្តី ទ្រង់យាងមកដល់ប្រទេសនិសធៈ ។ តាមផ្លូវដែលស្ដេចយាងមក មានលំអដោយកម្រងបុប្ផា ព្រះអង្គទ្រង់យាងលើផ្លូវកម្រងផ្កានោះ ។ នៅក្លោងទ្វារចូលព្រះរាជធានី ពួកនាម៉ឺនសព្វមុខមន្ត្រីធំតូចចាំទទួលព្រះអង្គ, ពួករដ្ឋមន្ត្រីថ្វាយសុន្ទរកថាមួយទទួលព្រះអង្គ ។ ទ្រង់បានឆ្លើយតបទៅវិញដោយរីករាយ, ព្រះនាងទមយន្តីក៏ទ្រង់ញញឹមអរគុណទៅវិញដែរ ។ ពួកប្រជានុរាស្ត្ររត់មកទទួលទ្រង់ឈូឆរ ។

ព្រះអង្គម្ចាស់បុស្ការៈ ទ្រង់ជ្រាបអំពីសេចក្ដីសុខសប្បាយនៃព្រះរាមដែរ ប៉ុន្តែទ្រង់រីករាយទៅពុំកើត ពីព្រោះទ្រង់ចេះតែមានទឹកព្រះភក្ត្រព្រួយជាធម្មតា ។ ទ្រង់ចេះតែគិតក្នុងព្រះទ័យជាយូរហើយថា: ‹‹ដល់ពេលដែលព្រះរាមអញត្រឡប់មកវិញ គួរអញទៅទទួលទ្រង់ឬគួរអញទៅពួនឲ្យបាត់?›› ។ ក្រោយបង្អស់ទ្រង់ផ្ដាច់គំនិតថានឹងត្រូវទៅទទួលព្រះអង្គដោយការគោរពតាមករណីយកិច្ចជាប្អូនគេ ប៉ុន្តែជាការចង់ប្រាបនូវកាតព្វកិច្ចសព្វគ្រប់ទេ ដែលទាញទ្រង់ឲ្យទៅវិញនោះមិនមែនជាសេចក្ដីស្នេហាសម្រាប់បងប្អូនឡើយ ។

ព្រះអង្គម្ចាស់បុស្ការៈ មិនបានជំអក់នៅក្នុងពិធីនោះយូរទេ ទ្រង់ក្រឡេកមើលព្រះនាងទមយន្តីដោយគ្នាន់ខ្នាញ់ ហើយមានបន្ទូលសរសើរ

ព្រះបាទនាលៈនឹងព្រះនាងទមយន្តីដោយព្រះនេត្រកំបុតៗ រួចទ្រង់ត្រឡប់មកព្រះរាជដំណាក់វិញភ្លាម ។

នៅពេលដែលទ្រង់ចានភ្ញារព្រះរាជដំណាក់ទើបចូល ស្រាប់តែមានដៃមួយដាក់មកលើស្មាទ្រង់ៗ ភ្ញាក់ក្រញាង ហើយបែរព្រះភក្ត្រទតទៅខាងក្រោយទាំងភ័យ ព្រះអង្គទ្រង់ឃើញបុរសម្នាក់មានមុខអាក្រក់នៅពីខាងក្រោយទ្រង់ ។ ទ្រង់មានបន្ទូលសួរថា: "អ្នកណា ហ្នឹង? មានការណ៍អ្វី?" ។

បុរសនោះឆ្លើយថា: "ចូលទៅខាងក្នុងសិន" ។ ព្រះអង្គម្ចាស់ពុស្ករៈក៏យាងចូលទៅជាមួយនឹងបុរសចំឡែកនោះ លុះបិទទ្វារជិតកាលណា បុរសនោះក៏ទូលទ្រង់ថា: យើងចង់ឲ្យទ្រង់បានសេចក្តីសុខទេបានជាយើងតាមទ្រង់មក, យើងស្គាល់នូវគំនិតរបស់ទ្រង់ ទ្រង់នឹងអត់ទ្រាំមិនទទួលនូវជាគក់ស្នាដ៏ប្រសើររបស់ខ្លួនម្តេចបាន, បើដូច្នេះបូរទ្រង់ស្តាប់ដំបូន្មានយើង, មិនយូរប៉ុន្មានទេ បងទ្រង់នឹងធ្លាក់ទៅជាលំបាកគោកយ៉ាកជាទីបំផុត ហើយទ្រង់នឹងបាននូវរាជសម្បត្តិដ៏ថ្លៃថ្លានេះ" ។

– ចុះឯងដែលមកពោលពាក្យសន្យាដ៏ប្រសើរយ៉ាងនេះ តើឯងជាអ្វី? ។

– យើងជាកាលិទេព ។

– ជាកាលិទេពមែនឬ? ។

– ហ្នឹងហើយ ជាកាលិទេពដែលគេតែងតែស្អប់ខ្ពើម ប៉ុន្តែជាដូចម្តេចក៏ជាទៅចុះ! យើងមិនមែនអន់ថយអានុភាពព្រោះតែពាក្យគេហា-

និន្នាប៉ុណ្ណោះទេ, គេយកឈ្មោះយើងទៅសំអុយក្នុងការទុច្ចរិតនៅពេលលេងល្បែងឡុកឡាក់ ។

- បើដូច្នេះ មានតែឯងឈ្មោះកាលី? ។

- ហ្នឹងហើយ យើងឈ្មោះកាលី, អ្នកលេងណាដែលយើងមានចិត្តគំនុំគុំគួន, អ្នកលេងនោះនឹងកើតអន្តរាយ នឹងចេះតែអភ័ព្វ ហើយនឹងបង់អស់ទ្រព្យសម្បត្តិ ។

- ឯងគំនុំនឹងព្រះបាទនលៈឬ? ។

- យើងចង់បានព្រះនាងទមយន្តីជាភរិយា ប៉ុន្តែនលៈមកកាត់មុខយើងជាអាទិទេព; ឯព្រះឥន្ទ្រាធិរាជ ព្រះអគ្គី លោកលើកទោសឲ្យចំណែកយើងៗ មិនមែនមានចិត្តសប្បុរសដូចលោកទេ យើងមិនបោះបង់ការសងសឹកពោលឡើយ ។

ព្រះអង្គម្ចាស់ប៉ុស្ការៈ ទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់អាទិទេពកាលីដោយប្រុងប្រយ័ត្ន ហើយមានបន្ទូលសួរថា: "តើឯងឲ្យយើងធ្វើដូចម្ដេច?" ។

- ចូរទ្រង់បបួលព្រះបាទនលៈឲ្យមកលេងល្បែងភ្នាល់នឹងទ្រង់ យើងនឹងនៅពីក្រោយព្រះបាទនលៈ ហើយមានតែទ្រង់មួយទេដែលមើលយើងឃើញ, នៅពេលលេង គ្មានក្តាណាមួយដែលទ្រង់មិនឈ្នះទេ ។

ព្រះអង្គម្ចាស់ប៉ុស្ការៈឆ្លើយថា: "ឯងនាំឲ្យយើងចង់លេងមែន ចួនកាលព្រះពមយើងទ្រង់មានព្រះទ័យចង់ក្រសាលដែរ" ។

អាទិទេពកាលីបង្គាប់ថា: "ចូរទ្រង់ទៅចាំស្កាត់ផ្លូវស្តេច កាលណាទ្រង់ធុញទ្រាន់នឹងការពិភាក្សាអំពីរឿងផ្សេងៗ ក្នុងព្រះរាជអាណាចក្រ ទ្រង់ទៅនិយាយយ៉ាងដូចម្ដេច ឲ្យតែទ្រង់សព្វព្រះទ័យនឹងលេងជាមួយទ្រង់ ទ្រង់នឹងបានសប្បាយជាមិនខាន" ។

ព្រះអង្គម្ចាស់ប៉ុស្ការៈដាក់ព្រះនេត្រចុះសញ្ជឹងគិត ហើយក៏សួរទៅកាលីថា: "ចុះបើសិនជាទ្រង់មិនព្រមលេង?" ។

ប៉ុន្តែកាលីក្បៀសខ្លួនចេញបាត់ទៅ ។

* * *

## វគ្គទី ១៣

ព្រះបាទនាលៈទ្រង់បំពេញព្រះរាជកិច្ចក្នុងប្រទេស ទ្រង់បើកការប្រជុំរាល់ថ្ងៃ ជាមួយនឹងទីប្រឹក្សា, លុះបានសំរេចការដែលមានសន្តិភាពហើយ ទ្រង់ទៅរកព្រះនាងទមយន្តីក្សាម ពេលដែលទ្រង់គង់នៅជិតព្រះនាងជាពេលដ៏ប្រសើររបស់ទ្រង់ ។

ទោះព្រះអង្គចង់ក្រសាល ក៏ទ្រង់មិនដែលទតឃើញល្បែងឡុកឡាក់ដែរ ។ ព្រះអង្គម្ចាស់ប៉ុស្ការៈនៅតែគិតមមៃដល់ពាក្យអាទិទេពកាលីដែលថានឹងបានជាស្តេចសោយរាជ្យ ទើបទ្រង់ព្រះចិន្តាថា "បើ

អញនឹងបានជាស្ដេចសោយរាជ្យ ដោយគ្មានទៀយព្រួយ ព្រោះតែឈ្នះល្បែងឡុកឡាក់ប៉ុណ្ណោះ! ចុះហេតុអ្វីក៏អញចេះតែមិនដាច់ស្រេចទៀត", គិតដូច្នោះហើយ ទ្រង់ក៏គិតឧបាយនាំព្រះរាមឲ្យចុះក្នុងល្បែង ។

ព្រះបាទនាលៈ ទ្រង់យាងចេញពីទីប្រជុំ ។ ព្រះអគ្គម្ចាស់បុស្ការៈក៏ទ្រង់យាងពីរបីជំហានទៅជិតស្ដេច ទ្រង់ធ្វើជាញញឹមរកព្រះរាម ហើយមានបន្ទូលថា: "ព្រះរាមមានរឹតមាំណាស់ ឥឡូវនេះ ព្រះអង្គលែងសព្វព្រះហឫទ័យនឹងល្បែងទៀតហើយឬ?" ។

ព្រះបាទនាលៈ មានបន្ទូលតបដោយទឹកធ្លូលវិញថា: "ល្បែង!" ហើយមានបន្ទូលតទៅទៀតដោយរីករាយថា "មែនហើយ កាលពីមុនមានពេលខ្លះ បងចូលចិត្តលេងល្បែង ហើយបុស្ការៈឯងមិនចូលចិត្តលេងផងទេ បើសិនជាឯងចូលចិត្តលេង១ទៅ ប៉ុន្តែប្អូនឯងរកអ្នកណាឯទៀតក្រៅពីបង, ចុះឲ្យបងឈប់នៅលេងម្ដេចបាន បើបងមើលឃើញព្រះនាងទមយន្តីចាំបងនៅក្នុងឧទ្យានឯនោះ" ថាហើយស្ដេចយាងហួសទៅ ។

ព្រះអគ្គម្ចាស់បុស្ការៈ ត្រឡប់ចូលដំណាក់វិញ ដោយអៀនអន់ ។ ក្នុងពេលនោះ ទ្រង់ឃើញកាលីនៅក្នុងមហាប្រាសាទ ទ្រង់មានបន្ទូលថា: "ឯងមកទៀតហើយ! ប្រហែលជាឯងដឹងថា ព្រះបាទនាលៈ មិនព្រមលេងនឹងយើងឬ?" ។

– កុំអាលព្រួយ, ចូរទ្រង់លុះក្នុងគំនិតទ្រង់ឲ្យមែនទែន បើព្រះបាទនាលៈមិនព្រមនៅពេលនេះ ពេលស្អែកទ្រង់នឹងព្រមតាម, ចាំពីរបីថ្ងៃទៀត ទ្រង់នឹងទៅចួបព្រះបាទនាលៈ ហើយបបួលឲ្យលេងទៀត ចូរទ្រង់កុំក្រែងថាទ្រង់មានបង្អែកយ៉ាងចំណាន" ។

ប៉ុន្តែ ព្រះអង្គម្ចាស់បុស្ការៈខំទទូចទទែយ៉ាងណា ព្រះបាទនាលៈក៏នៅតែប្រកែកថា: "កុំបញ្ឈប់បងធ្វើអ្វី បងនឹងទៅកន្លែងណាដែលបងឃើញនាងទមយន្តី, ចុះឲ្យបងលេងធ្វើអ្វី តែបងលេង បងខាតពេលនឹងបានឃើញព្រះនាងញញឹម" ។

* * *

### វគ្គ ទី ១៤

លុះអំឡុងយូរទៅ ព្រះបាទនាលៈនឹងព្រះនាងទមយន្តីមានព្រះរាជបុត្រាមួយព្រះអង្គនឹងព្រះរាជបុត្រីមួយព្រះអង្គ ។ នៅពេលសម្រាកព្រះបាទនាលៈ មិនត្រឹមតែមកនូវព្រះឯកអគ្គមហេសីជាទីស្នេហាប៉ុណ្ណោះទេ, ថែមទាំងទ្រង់ទតព្រះរាជបុត្រទាំងពីរព្រះអង្គ ដែលទ្រង់តែងតែនាំលេងល្បែងនានាតាមរបៀបក្មេងចូលចិត្តផង ។ ទ្រង់បង្កើតល្បែងផ្សេងៗជាច្រើន ដែលមិនដូចនឹងល្បែងឡុកឡាក់បន្តិចសោះ ។

ព្រះអង្គម្ចាស់បុស្ការៈ មុនដំបូងទ្រង់មានសង្ឃឹមថានឹងសម្រេចបំណង តែឥឡូវនេះទ្រង់បែរទៅជាអស់សង្ឃឹមវិញ ។ កាលខំតែលើកទឹកព្រះទ័យព្រះអង្គម្ចាស់បុស្ការៈ តែមិនបានសម្រេចដូចបំណង ។ (មានត)

ដំណើរអស្ចារ្យនៃលោកតាក៉ាស្ទីរប្យុយេ

លោកឞូគុស៊ី រៀបរៀង

លោក រ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ពាសីនោះជាស្រីក្ដកករកុហកសោះ ព្រោះអ្នកជិតខាងខ្ញាបរឆោត្រជាក់, បានប្រើឧបាយដោយឲ្យពាសីនេះទៅកុហកដូចនេះ; គឺនាងមកបង្ខំឲ្យអ្នកម្ចាស់ផ្ទះវិលត្រឡប់ចូលទៅក្នុងគេហដ្ឋានវិញ ហើយអ្នកនេះបានពោលថា ជាជោគវាសនាអាក្រក់ បានជាមានគេមកបង្ខំមិនឲ្យមើលទស្សនិយភាពដ៏ប្រសើរដូចនេះ ៗ តែអ្នកស្រីជាម្ចាស់ផ្ទះដែលបាននូវបរិយានៃអ្នកជិតខាងអញ្ជើញមកដល់ទីនោះជាលំដាប់ ហើយពោលថា: "គេទើបនឹងយកនូវសីវិត្តគីនបង្អប់សាច់គ្រសារ ហើយមានតែលញ់មេញាធ្វើនំផ្សេង ៗ, សូមអ្នកអញ្ជើញពីសាតែជាមួយនឹងយើង" ៗ ហើយអ្នកជិតខាង (សមន្តជន) បានសូមអភ័យទោសអ្នកស្រីហើយថ្លែងជំរាបអ្នកស្រីថា: "ខ្ញុំបានទទួលទាននូវសំឡ (ស៊ុប) សាច់ក្មេក ហើយមិនសូវមានឧជារសផង អ្នកស្រីបានជ្រាបស្រាប់ហើយថា មាន

គេឲ្យខ្ញុំទៅ ផ្សិតមានការប្រញាប់ ខ្ញុំសូមថ្លែងនូវសេចក្ដីស្តាយពន់ពេកចំពោះអ្នកស្រី, សូមទោសអ្នកស្រី" ។

នេះគឺចំនៀមទម្លាប់ប្រពៃណីនៃប្រទេសនេះ ចំពោះបងប្រុសនឹងកល្យាណមិត្ត ក៏ត្រូវតែអត្តអាងដោយពាក្យប្រាប់ៗគ្នា ។ ពួកនេះ សុទ្ធតែពួកឧត្តរិជន (hypocrètes) ពោលតែពាក្យកុហក ។ លោកក៏សូប៊ី-យូយេ ក៏ធុញទ្រាន់នូវកិច្ចការទាំងប៉ុន្មានដែលលោកបានឃើញ - ក្នុងប្រទេសនេះ ហើយក៏ជិះក្រសារហោះចេញតម្រង់ទៅកាន់ប្រទេសមួយផ្សេងទៀត ។

## គតិអ្នកនិពន្ធ

ក្នុងពេលដែលយើងរស់នៅដោយសន្តិភាព កែងដៃយើងលាត់ដូចជាដងស្រែកសម្រាប់រែកទំនិញ ក្បៀងធ្លាក់បន្តិចជាអន្តរកាសមួយ ធ្វើឲ្យយើងស្ថិតនៅក្នុងត្រីហា, ហើយក៏ប្រើពេលវេលានោះសម្រាប់លេងកំសាន្តខាងល្បែងផ្សេងៗ នឹងក្លេងមហោស្រពតូរ្យតន្ត្រី ។ មនុស្សទាំងអស់ធ្វើខ្លួនឲ្យវិនាសដោយការសេពនូវសុរា បរិភោគអាហារច្រើនហើយនឹងកាត់ខោអាវដ៏មានដំឡៃ ហើយមានការខ្វះខាតជានិរន្តរ៍ក្នុងកិច្ចចំណាយនូវថវិកាខាងគ្រួសារ ។ អ្នកទាំងអស់នោះ មិនព្រមយល់ថាការចំណាយមិនគ្រប់គ្រាន់មកពីខ្លួនប្រព្រឹត្តអករណីយកិច្ច : ទៅជាបន្ទោសពេលា, ដាក់កំហុសទៅដល់ជនដទៃ ហើយចោទប្រកាន់ពិភពលោកថាបង្កើត

ឧបសគ្គរាំងរាមិនឲ្យសម្រេចនូវប្រយោជន៍បាន ។ វត្ថុបំណងដ៏សំខាន់ គឺការសប្បាយចិត្តនិងសេចក្តីប្រាថ្នាចង់ធំចង់ខ្ពស់ប្រសើរ ដែលនាំឲ្យខ្លួនព្យាយាមបំពេញវប្បកម្មខាងការប៉ិនប្រសប់ក្នុងសង្គម ទុកជាអវសាននៃបំណងក្នុងជីវភាព ។ អ្នកទាំងនោះភ្លេចនូវលក្ខណសម្បត្តិចំពោះខ្លួនហើយទៅប្រព្រឹត្តដំកើងខ្លួនជាអភិជន ឬជាសេដ្ឋី ។ អ្នកទាំងអស់ធ្វើដូចនេះ បើតាមបរិយាក្រៅថាធ្វើដោយមិត្តភាព, ទម្រង់នៃពិធីបុណ្យ ឬ ករណីយកិច្ច; តែបើតាមពិត គឺមានបំណងចង់ឲ្យអាប់កេរ្តិ៍ឈ្មោះនៃមិត្តទាំងឡាយ ហើយនឹងតាំងខ្លួនជាអ្នកមានទ្រព្យសម្បត្តិ ឬ ជាអ្នកបេះជាងគេទាំងអស់ ។ ពួកទាំងនោះ ដូចជាមនុស្សខ្សោយប្រាថ្នាចង់លើកបារអង្ករ; មុខគួរឲ្យស្តាយពន់ពេកថាយើងធ្វើខ្លួនយើងឲ្យមានទុក្ខលំបាកមកពីមានៈ, ពិតមែនតែយើងមិនបានធ្វើវត្ថុអ្វីជាច្រើន តែយើងគង់ជាកូនបំណុលចំពោះអ្នកទាំងអស់ ។ មានមនុស្សជាច្រើន មានគុណសម្បត្តិល្អក្នុងខ្លួន តែធ្វើគុណសម្បត្តិនោះឲ្យខូចវិនាសៈទៅវិញ ។ អ្នកក្រមិនត្រូវខ្មាសអៀនទេ បើអ្នកក្រនោះមានអង្ករគ្រប់គ្រាន់បរិភោគ, មានសំលៀកបំពាក់ល្មមសមរម្យ, ត្រូវតែអ្នកក្រនោះសប្បាយចិត្តទៅវិញ ។ មនុស្សពិតនោះ តែងបង្ហាញក្នុងហទយវត្ថុរបស់ខ្លួនឲ្យពិភពលោកឃើញ ហើយគ្មានខ្លាចអ្វីឡើយ ។

*

* *

## ៤ — ធ្វើដំណើរទៅកាន់បុរាណនិយមប្រទេស

(Pays ducullte de l'Autiquité)

មនុស្សដែលធ្លាប់តែស្ថិតនៅក្នុងភូមិស្រុក ច្រើនគាណិតគាស្ងួរដល់អ្នកដំណើរដែលទៅមកអស់កម្លាំងដោយផ្លូវឆ្ងាយ, តែលោកព៉ីស្សូប៊ីយ៉ូយេ កាលដែលលោកបានអញ្ជើញទៅកាន់អមតប្រទេស ទៅជាមានកម្លាំងពេញលេញ ដូចពួកយុវ័នយល់ថាពិភពលោកទាំងមូលជាគេហដ្ឋានរបស់លោក ហើយសត្វក្រសារនោះក៏មានមនោសញ្ចេតនាដូចលោកដែរ, បានជាអ្នកទាំងពីរហោះទៅលើនភាល័យ, កប់ពពក, ក្រែបរសជាតិនៃមេឃស្រអព្ទ ហើយស្មានថាដុំទឹកកកជាគ្រាប់អង្ករ ។

លោកព៉ីស្សូប៊ីយ៉ូយេ បានឃើញប្រទេសមួយដែលលោកស្មានថាជាទីសប្បាយ លោកក៏ចុះនៅទីនោះ ។ ចំណែកខាងក្រសារកំពុងរលាស់ស្លាប ហើយលោកព៉ីស្សូប៊ីយ៉ូយេ កំពុងពត់អវយវៈ, ស្រាប់តែមានបុគ្គលជាច្រើនចូលមកហោមរោមលោក ដូចជាសៀវភៅដែលគេបើកសន្លឹកមួយៗ មានរូបគំនូរមនុស្សជាច្រើនចេញមកព័ទ្ធពេញដូចកោះ ។ ពួកជនទាំងអស់នោះក៏ថ្លៀងសោតបសាទស្តាប់ ដោយយកចិត្តទុកដាក់ពេញលេញអំពីសេចក្ដីពណ៌នានូវដំណើរទៅប្រទេសផ្សេងៗ នៃវីរបុរសនេះ, បានចាត់ឲ្យរកគេហដ្ឋានមួយស្អាតល្អសមរម្យសម្រាប់ឲ្យលោកពឹងពាក់អាស្រ័យ ហើយជំរាបលោកថាប្រទេសនេះនាមថា: "បុរាណ-និយមប្រទេស" ។

លោកកាំសូបីយូយេ លោកបានពិនិត្យឃើញដោយពេញចិត្តថា ពួកទាំងនេះកាន់តាមធម្មតា មិនមានអ្នកអាងអ្វីឡើយ, ពួកកសិករធ្វើស្រែចម្ការ, ពួកជាងឈើធ្វើគ្រឿងហា, ពួកពាណិជ្ជលក់ដូរទំនិញដូចពីបុរាណកាល, ហើយគេហដ្ឋានទីងគ្រឿងស្មៀកពាក់សុទ្ធតែជារបស់ចាស់ៗ ហើយដែលមានមកជាយូរកាល, ខ្ញុំពេញចិត្តចំពោះការប្រព្រឹត្តបែបនេះ, ខ្ញុំមិនចូលចិត្ត ។ មនុស្សល្អត្រូវប្រព្រឹត្តកិរិយារបស់ខ្លួន ដោយយកកិរិយាចិនពីបុរាណកាលជាទិដ្ឋានុគតិ ។ ពួកទាំងនេះស្រឡាញ់តែចាស់ ហើយពួកមនុស្សជំទង់ទីងប្រជុំគ្នាចំពោះតែការបូជាវិសជ្ជនាខាងទស្សនវិជ្ជាបុរាណ ។ ពួកអ្នកនិយមតាម (សាវ័ក) លោកកុង ហ្វូ-សឺ នឹងលោកមេង-សឺ មានខ្លះដែរ តែសាលារៀនមានៈច្រើនជាអនេកប្បការ ដល់គេរាប់ចំនួនទាំងអស់មិនបាន, ហើយការថែទាំរុក្ខជាតិដូចជាគ្រីសង់ថែម (Chrysanthèm) ឬរបៀបដាំចុស្សតែងយកក្បួនបុរាណជាទីតាំង ។

ពីរបីថ្ងៃក្រោយមកលោកកាំសូបីយូយេមកដល់, អ្នកបុរាណនិយមដែលនៅជិតលោក បានអញ្ជើញលោកទៅសន្និបាត ។ ដល់លោកអញ្ជើញទៅដល់បានចូលមកក្នុងបាហុនដ្ឋាន លោកបានពិនិត្យមើលកន្លែងនោះសុទ្ធតែរបនាក្បាច់សិល្បៈដែលមានគំនូរពណ៌ (ពាក្យជប៉ុនហៅថា កាកឺមូណូ (Kakemono) ដែលគេព្យួរនឹងជញ្ជាំង, នៅជើងជញ្ជាំង

នោះមានផ្កាឈូកដុះនៅក្នុងផើង ៗ បន្ទប់តពីនោះមក មានកូតូ (Koto) មួយនឹងស្ហូ (Sho) មួយដែលរង់ចាំអ្នកភ្លេងលេង ។ អ្នកម្ចាស់ផ្ទះទទួលភ្ញៀវ ពាក់អាវវែងគីមូណូ (Kimono) ពីបុរាណ ។ ភ្ញៀវដែលចូលមកដំបូង នៅក្នុងទីនោះជាសាវ័កលោក កុងហ្វុងស៊ី, បន្តិចទៀតមានពួកសាវ័កខាង មេង · ស៊ីបួនប្រាំនាក់ ហើយពួកទាំងអស់នោះ បានសំដែងនូវគារ-វភាពចំពោះអ្នកម្ចាស់ផ្ទះ ហើយក៏នាំគ្នាឈ្លោះអំពីរឿងថា ស្រាជាបុព្វហេតុ នៃសេចក្តីអាក្រក់ក្នុងលោក, រួចអ្នកទាំងអស់គ្នាក៏បរិភោគស្រានោះទៅ ៗ

ដល់អ្នកទាំងអស់សន្ទនាការទៅវិញ-មក ដោយបណ្ឌិតព្រមទាំង សេចក្តីគួរសម ស្រាប់តែមានពួកគណៈខាងសាលាសូស្ហ៊ី(១) មកដល់ ៗ

អ្នកនោះចូលទៅអង្គុយ, ច្រៀងបទពីរោះ, និងថ្លែងនូវរឿងរ៉ាវ ដែលគួរឲ្យសើច តែងធ្វើឲ្យអ្នកស្តាប់អាក់អន់ស្រពន់ចិត្ត ។ អ្នកម្ចាស់ គេហដ្ឋាន, ដើម្បីកុំឲ្យខ្មែមកបៀតបៀន បានគិតឲ្យគេលេងភ្លេង, លោក បានប្រកាសជាសាវ័កតូបូសកុ(២) (Tobosaku ហើយបានជូនស្រាមួយ ពែងគប់ៗគ្នា ទាល់តែភ្ញៀវទាំងអស់ក្រោកឡើងច្រៀងរាំ ដើរមិនស្រួល ទីង, វៀរលែងតែពួកសាវ័កលោក កុងហ្វុង-ស៊ី និងមិង-ស៊ី ។ ពួកទស្សន វិទូជាបណ្ឌិត (lettrés) ធ្វើចិត្តនឹងធួនហើយពោលថា៖ “លោកគ្រូយើងមាន

---

១ Ectateur de l Ecole de sashi ពួកគណៈខាងលទ្ធិលោកសូស្ហ៊ីគឺសន្តបុគ្គល ពេញចិត្តខាងភ្លេង ។ ២ តូបូសកុ ទីប្រឹក្សានៃព្រះអធិរាជចិនក្នុងសន្តតិវង្សហ័ន ។

វិចារណញ្ញាណត្រូវត្រូវការពោលថា ក្មេងសាមញ្ញនឹងចម្រៀង ពួកបណ្ឌិតត្រូវលះបង់ឲ្យផុតស្រឡះពីសណ្ដានចេញ" ។ អ្នកម្ចាស់ផ្ទះឆ្លើយតបវិញថា: "តើបានប្រយោជន៍អ្វីត្រង់ការតាំងខ្លួនជាបណ្ឌិត ជីវភាពរបស់មនុស្សមិនដែលមានផ្កាម្ដងទៀតឡើយ" ហើយអ្នកម្ចាស់ផ្ទះនោះក៏ច្រៀងតទៅទៀត ហើយថែមទាំងបរិភោគនូវសុរា ។ ពួកបណ្ឌិតទៅជាមានចិត្តមិនទឹងទួនដូចប្រក្រតី. ត្រឡប់ទៅជាក្មួយចៅនៃលោក កុងហ្វុង-សឺ ទឹងមិង·សឺ ហើយមានសាវ័កម្នាក់ស្រែកឡើងថា: "គេបានទិតន្ទមកថា ត្រូវតែពិសោធន៍នូវរឿងរ៉ាវសព្វគ្រប់ចំពូកក្នុងពិភពលោក ហើយជ្រើសរើសនូវអ្វីដែលវិសេសជាងគេ" ។ ពួកសហជីវិននៃសាវ័កនោះក៏បានឲ្យពរសព្ទសាធុការ ហើយប្រុងប្រៀបនឹងផឹកស៊ី ច្រៀង, រាំ តាមបំណង, ហើយពោលពាក្យដូចនេះថា: "ត្រូវតែមនុស្សណាជាបណ្ឌិតផឹកស្រាទំពាំងបាយជូរ ដើម្បីរចនាខ្លួនឲ្យទៅជាបណ្ឌិតកាន់តែប្រសើរឡើង" ហើយពួកនោះក៏នាំគ្នាសប្បាយអស់យូរកាល រួចត្រឡប់ទៅគេហដ្ឋានវិញជិតភ្លឺ ។

សាវ័កនៃពួកមហាបណ្ឌិតប្រទេសចិនតែងមាននាមល្បីល្បាញនាពិភពលោក ។ តែមិនយូរប៉ុន្មាន, ពួកនេះទៅជាមានចំនួនតិច, ចំណែកខាងពួក (យេន-សេន-ដូ Yen-g-n do) ជាទស្សនវិទូលេងល្បែងគ្រប់យ៉ាង ហើយនឹងពួកខាង ចូសាន-ស៊ី (Chosan-Sei) ជាទស្សនវិទូសេពសុរានឹងមេវ័យ កាន់តែទ្វេចំនួនជាលំដាប់កល់ទំរាំពេក្រៃ ។ អ្នកបុរាណនិយមកាន់តែ

មានចិត្តសប្បាយពន់ពេក ដោយការជោគជ័យរបស់លោកទៅលើពួកបណ្ឌិត (lettrés) ទាំងនោះ ហើយលោកក៏ខំព្យាយាមសូត្ររៀនទូវទស្សនវិជ្ជានៃគណៈសាសនាឯទៀត, ដូចជាគណៈ រិហាកុ (Rihaku) អ្នកកវីស្រវឹងស្រា ។ លោកប្រព្រឹត្តព្យាយាមចំណាយប្រាក់ជាច្រើនក្នុងរឿងនេះទាល់តែធ្លាក់ក្រ, គោកទ្រព្យទាំងប៉ុន្មានរសាត់បាត់ដូចមេឃបុះអ័ព្ទ ហើយគេលែងឃើញផ្សែងចេញពីគេហដ្ឋានរបស់លោក ។ លោកក៏ដួលខ្លួមគេមួយនៅហើយបរិភោគតែនំបុ័ងដែលធ្វើពីបុងអង្ករ, តែលោកបរិភោគស្រាទំពាំងបាយជូរ ហើយច្រៀងសរសើរពីខ្លួនលោក ៗ ពោលថា: "ពួកសេដ្ឋីគ្មានបណ្ឌិត ។ បើអ្នកឯងមិនស្គាល់ក្រ; អ្នកឯងមិនយល់នូវទុក្ខទោរបស់បណ្ឌិតឡើយ ។ ឋានៈទឹងជោគវាសនារបស់មនុស្សមិនស្ថិតស្ថេរប្រៀបដូចពពកដូចនោះ ។ ក្នុងពេលនេះ ខ្ញុំកំពុងរស់នៅពិតប្រាកដ" ។ ហើយលោករៀនសូត្រដោយរស្មីសត្វអំពិលអំពែក, បរិភោគស្រាទំពាំងបាយជូរនៅក្នុងភូម, ហើយបើកាលណាលោកអផ្សុកលោកពាក់មួកមួយទឹងអាវវែងធ្វើពីចំបើងហើយកាន់ចបដំរះមួយ, លោកព្យាយាមដកទំពាំងឬស្សីពីដី ដែលមានទឹកកកនៅពាសពេញ, ឬវាយបំបែកទឹកកកនៅក្នុងបឹងដើម្បីទឹងចាប់ត្រី, ធ្វើយ៉ាងដូចនេះ គឺដើម្បីឲ្យមាតារបស់លោកពិសាបាយម្ហូបចំណីឲ្យឆ្ងាញ់ (១) ។ តែលោកមិនបានប្រយោជន៍អ្វី បែរឃើញតែកើតពេគ្គាសាយទៅវិញ ។ កិរិយារបស់

១ ឧទាហរណ៍ប្រៀបធៀបទៅខាងកតញ្ញូចំពោះមាតាបិតា, ជាប្រពៃណីមួយប្លែក ។

លោកដែលយល់ថា ស្វាមីធ្វើអំពើបែបនេះជាសភាពធ្ងន់ បានយំទួញ ដាស់តឿនលោកកុំឲ្យប្រព្រឹត្តយ៉ាងនេះតទៅទៀត ហើយឲ្យវិលមករកសុភនិច្ច័យតាមធម្មតាទៅវិញ, តែលោកតបទៅភរិយាវិញថា:

"ធម្មតាមនុស្សជាបណ្ឌិត មិនត្រូវស្តាប់ដំបូន្មាននៃភរិយាឡើយបើគ្មានចិត្តខ្ទីនឹងថាមភាព គេមិនអាចសម្រេចនូវគតិបណ្ឌិតបានឡើយ" ។

បើមាតាលោកស្តីបន្ទោសអ៊ីលោកតបទៅវិញថា "មាតានេះ មានគំនិតថោកទាប ហើយមិនអាចប្រព្រឹត្តតាមបាន ដូចជាមាតានៃបុត្រជាបណ្ឌិត" ។ ព្រោះហេតុដូច្នេះ បានជាមាតានឹងបុត្រតែងឈ្លោះទាស់ទែងគ្នាទាល់តែមាតានោះដកហូតយកគ្រឿងមត៌កជាអវសាន ។ (មានត)

### រៀនបេះខ្ជិលល្ងង់

ជាតិកូនប្រុស ត្រូវឲ្យលុះ ផ្លូវសិក្សា
រៀនលុះត្រា ចាស់ជរា ជីវិតមរណ៍
រៀននេះបះ ត្រូវកុំធ្វេស រៀននោះត
កាលបើមរណ៍ គ្រឿងមាន មិនបាត់បង់ ។
ជាតិកូនស្រី ក្នុងលោកិយ ក៏ដូចគ្នា
មិនត្រូវភា ផ្លូវវិជ្ជា ដោយថ្មអគ្គ
វិជ្ជាអ៊ី ទោះប្រុសស្រី ក៏ត្រូវផង
រៀនបុរគង់ កើតសួស្តី មិនអាក់ខាន ។

យ. អ៊ី.

ដំណើរតាមច្បាស់ក្នុងគន្ធារៈ

# លោក ផេង-ជ្រឿវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

អ៊ីស្មាអ៊ីលខឹងមុខឡើងស្លេក ប៉ុន្តែគេបេះទប់ចិត្តបាន គេមិនបង់ឈ្មោះតនឹងសៀម ព្រោះការជំលោះនេះនឹងតែធ្វើឲ្យឪពុកគេដែលចាស់ដកនឹងមានសេចក្តីព្រួយ ម៉្លោះហើយគេខំអត់សង្កត់កំហឹងដែលលុកលុយក្នុងខ្លួនសន្តាន គេគំនាប់ពួកក្មេង រួចគំនាប់ឪពុក ហើយងាកទៅឱបប្អូនឈ្មោះមុក្តា ទើបដើរចេញទៅ ។

ប្រហែលមួយស្របក់មក គេឮសូរជើងសេះដើរលើឥដ្ឋក្រាលក្នុងទីធ្លា ហើយបន្តិចមកទៀត ស្រាប់តែឮសូរសេះផាយចេញបាត់ទៅ ... ។

ខណៈនោះ លោកតាបេគី-ដៃរណា ក៏ដូចលោកអៃយ៉ាដដែរ គឺជាចាស់ព្រឹទ្ធាចារ្យ ជាទីគោរពជាងគេក្នុងស្រុក ចាប់ផ្តើមក្រោកបន្តិចៗឡើង ហើយអ្នកឯទៀតក៏ធ្វើតាមទាំងអស់ ។

លោកដើរតម្រង់អាសនៈពួកដែលលោកអៃយ៉ាដអង្គុយ ហើយចាប់ឱបការឹតដោយដៃទាំងពីរ ប្រជល់ថ្ពាល់គ្នាអស់វាងពីរបីនាទី ជាសញ្ញានៃមេត្រីចិត្តនឹងសេចក្តីទុក្ខព្រួយ ។ លោកមានប្រសាសន៍ថា:

– អៃយ៉ាដ! កូនប្រុសឯង អស់សង្ឃឹមនឹងនៅជាមួយយើងហើយ! ត្រូវប្រយ័ត្នខ្លាចក្រែងព្រះអាទ្យស៍មិនពេញចិត្ត! គំនិតថ្មីនឹងកាមពុកនៃប្រទេសអឺរ៉ុបរំលួយអ៊ុស្មាអ៊ុលហើយ ។ កងសម័យដែលយើងកំពង់តាំងនៅក្រោមអំណាចនៃទុរាចារ្យធម៌នេះ ចំណែកគេទៅជាហានអះអាងជួយការពារថាជាអារ្យធម៌ល្អវិញ ដែលជាធម៌ធ្វើឲ្យយើងពល់គ្នាស្មើរនឹងរលួយប្រមាត់ថ្លើម ឱមោឃបុរស! ។

លោកអៃយ៉ាដ អឺតមិនថា គ្រាន់តែថា ។

សំដីរបស់មិត្តចាស់ប៉ុណ្ណោះ ហាក់ដូចគេយកឈើស្រួចមករុកមុខរបួសរបស់លោកអៃយ៉ាដឲ្យរឹងរឹតតែរីកធំឡើង ។ លោកធ្វើសញ្ញាចំពោះកូនបន្ទាប់របស់លោកដែលមានទឹកមុខប្រកបដោយបញ្ញា ហើយទៅជួតឈូត ឲ្យចូលមកជិត ដ្បិតមុក្តានៅមានចិត្តស្មោះត្រង់មិនលះបង់សំលៀកបំពាក់ដែលជាកេរ្ដិ៍ដំណែលពីដូនតាមក នឹងគំនិតរបស់ជាតិ ។

លោកគាបេត្រី-ដៃរណា សំឡឹងចំពោះប្អូន នៃអ៊ុស្មាអ៊ុល ដោយទឹកមុខមានសេចក្ដីស្នេហា ហើយនិយាយថា:

– អៃយ៉ាដ កុំព្រួយអី! មុក្តាជាកូនដ៏បរិសុទ្ធរបស់ឯងហើយ ។ គេមុខជាមិនធ្វើឲ្យឯងព្រួយទៀតទេ ។

លោកអៃយ៉ាដឱបកូនបន្ទាប់នៅដើមទ្រូង ព្រោះឥឡូវលោកសង្ឃឹមតែលើរូបគេមួយ ។

ពួកភ្ញៀវជូនគំនាប់ម្ចាស់ផ្ទះម្នាក់ម្តងៗ ហើយនាំគ្នាចុះចេញទៅដោយការស្ងៀមស្ងាត់ ៗ មិនយូរប៉ុន្មានលោកអៃយ៉ាំងនិងមុក្តានៅស្ងាត់តែពីរនាក់ក្នុងបន្ទប់ ៗ

វេលានោះ អ្នកកំលោះឱនថើបដៃលោកឪពុកដោយការគោរពយ៉ាងខ្លាំង លុះងើបឡើង គេឃើញទឹកភ្នែកហៀរហូរពេញតែភ្នែកលោកឪពុកជាទីស្នេហា ៗ

* * *

នៅឯក្រៅ ពួកភ្ញៀវនាំគ្នាថយទៅទីលំនៅរៀងខ្លួនតាមពួកដោយស្ងៀមស្ងាត់គ្រប់គ្នា គឺសេចក្តីទុក្ខឥតឧបមាគ្របសង្កត់ បណ្តាលមកពីអធិករណ៍ដែលទើបនឹងកើតមានឡើង ព្រោះអ្នកទាំងអស់ពេញចិត្តចំពោះបញ្ហាកំឡាំងកាយនឹងធម៌សប្បុរសរបស់អ៊ីស្មាអ៊ីល ហើយឥឡូវអ៊ីស្មាអ៊ីល មិនបានរាប់បញ្ចូលក្នុងចំណោមគាប់ឡើយ គឺជាសេចក្តីវិនាសមួយយ៉ាងធំ ៗ អ្នកទាំងនេះព្រួយខ្លាំងដោយមានសេចក្តីស្នេហាចំពោះអ៊ីស្មាអ៊ីលគ្រប់រូប... បណ្តាជនទាំងប៉ុន្មាន មានតែស្ប្រៀមម្នាក់ឯងទេដែលថយទៅផ្ទះវិញប្រកបដោយសេចក្តីកេកយ ៗ

## ឆាងឡឺឡា

ព្រះពាយដែលបក់មករំភើយៗ បែបត្រជាក់លើទីវាល ឲ្យដំណឹងថាពេលព្រលប់នឹងយប់ជិតមកដល់ហើយ ៗ ស្លឹកត្នោតស្លឹកស្វាថ្ងៃតាំង

ត្រីខ្យល់ ធ្វើឲ្យឃើញពណ៌ក្រហមដូចស្ពាន់ ហេចក្ដៅចុះក្ដៅឡើង បំណែកស្លឹកបេកត្រូវបំណាំងថ្ងៃភ្លឺផ្លេកៗ ដូចកញ្ចក់ ។

នៅលើចង្កេះភ្នំដែលជាទីសំណាក់អាស្រ័យ នៃគណៈលោកតាម៉ា ព្រែកអែលគាឌី ដើមអាកាស្យាផ្កាបង្កោមៗ ពណ៌លឿងផ្សាយគន្ធពិដោរ តាំងពីព្រលឹមមក ។ បំណែកផ្កាម៉ីមូហ្សាស់ លាត្របកទទួលខ្យល់មក ពីទិសទក្សិណ ។ ក្នុងទឹកជ្រោះទឹកត្រពាំង ផ្កាព្រលឹតផ្កាឈូកត្របក សរីកក្របានៗ ចាំទទួលពន្លឺព្រះអាទិត្យនាវេលាល្ងាច ។ យូរៗ គេឮ អនង្គកសត្វយំ សត្វត្រកួតថ្ងូរ ទីងស្វាស្រែក ។

សត្វអូដ្ឋដេកទំពាអៀង ធ្មេញកករលីវ នៅជាចន្លោះដុំប្រក់សំពត់ ឡើងពណ៌ប្រផេះដោយថ្ងៃចាំង ឡើងពន្លកដោយទឹកភ្លៀងហូរដាក់ ព្រោះប្រើមកជាយូរឆ្នាំទីងច្រើនកន្លងហើយ ។ ចួនកាល គេឃើញ ស្ត្រីខ្លះស្លៀកសំពត់ពណ៌ឆើត ទទួរក្រមាបិទមុខ ចេញក្ដៅពីក្នុងដុំ ហើយប្រញាប់ទៅដកល់ឆ្នាំងលើជើងក្រានដែកបីជើង ដាក់លើចម្អួយដុំ សំប៉ែត ។ គេចាប់ស្ងោរសាច់ ឬ ស្ល ។ គឺជាដុំសាច់ចៀម ក្ដៅកូន ពពែ ឬ មាន់ទាផ្សេងៗ យកមកស្ងោរ ហើយយកស្លឹកដំរមេះក្រៅផ្ទៃ ដំបូទីងអង្ករមកជាគ្រឿងផ្សំ ។ ក្នុងពេលថ្ងៃរសៀលមានតែចាស់ៗ ទេ នៅចាំដំរ ។ ពួកចាស់ៗ នាំគ្នាអង្គុយលេងនៅមុខផ្ទះសំពត់ លើទី លានទោសយ៉ាងស្អាត ព្រោះខ្សាដំរច្រើនណាស់ ហើយទំពាស្លឹកម្លូ

ស៊ីធ្វើព្រៃហើយ ។ ពួកកូនក្មេងស្ទៀងតែនាំមកលេងក្បែរៗ ចាស់ហើយមិនយូរប៉ុន្មានស្រាប់តែនាំគ្នាអង្គុយព័ទ្ធជុំវិញចាំស្តាប់រឿងក្នុងកន្ទារៈ (Dósart) គឺគេនិយាយអំពីសត្វសាហាវធំៗ ក្នុងព្រៃ ពស់ ហើយច្រើនតែរៀបរាប់អំពីខ្មោចទឹកនឹងអារក្សអ្នកតាដែលមានអានុភាពខ្លាំង ។

ពួកប្រុសៗដែលជាល្អ ចេញទៅតាំងពីព្រលឹម នាំគ្នាយកទំនិញនិងសម្ភារៈផ្សេងៗ ទៅលក់ឯទីក្រុងជិតខាង ។ ពួកអាក៏ប៉ដើរទេសមិនមែនជាពួកចោរប្លន់ទេ គេសុទ្ធតែជាអ្នកធ្វើជំនួញ គឺយករបស់ដែលខ្លួនធ្វើនឹងទំនិញដែលទិញមកពីក្រុងធំ ទៅដើរលក់ពីភូមិមួយទៅភូមិមួយដរាបទាល់តែអស់របស់ទើបត្រឡប់មកវិញ ។

អាក៏ប៉ដើរទេសគណៈលោកតាម៉ាព្រក សុទ្ធតែមនុស្សសុចរិតរកស៊ីធ្វើរបរជំនួញ ។ ជីវភាពតាម៉ាព្រកតែងប្រព្រឹត្តទៅជារបៀបអ្នកដើរទេសតាំងពីក្មេងមកក្នុងវាលកន្ទារៈ ។ អាពុកគាត់ស្លាប់ទៅ គាត់ឡើងកាន់ឋានៈជាមេគណៈជំនួសតាំងពីកាលគាត់អាយុម្ភៃឆ្នាំ ។ គាត់រកទទួលទានបែបនេះរាងសែសិបឆ្នាំមកហើយ តែងដើរទៅដើរមកក្នុងកន្ទារៈនាកំឡុងក្រុងទីប៉ូលីតែន ។ ជំនួញដែលគាត់ធ្វើ គឺឡេវអាវកិប សំពត់សំបកឈើស្បែកសត្វអូទ្រេះ ស្បែកពពែសំឡាប់ហើយ កប្បាស ភ្លុក កូនកន្សែងដៃសំពត់អង់គ្លេស ម្ទេស ផ្លែដីប៉ូ ម្រេច ស្ករតែ សំពត់សាក្លាតប្រទេសអូទ្រិះពណ៌ក្រហម ខៀវ បៃតង លឿង ដើម្បីយកមកធ្វើសំលៀកបំពាក់អាក៏ប៉ នឹងវត្ថុដទៃទៀតជាច្រើនដែលអ្នកស្រុកអាយត្រូវការ ។

ពួកឈ្មួញការនាំតែធំបន្តិចម្តងៗ មកពីពួកអ្នកដំណើរទេសចរផ្សេងៗ បានប្រមូលគ្នាក្នុងកន្លែងនោះ ហើយនាំគ្នាធ្វើជាគណៈមួយយ៉ាងធំដើម្បីជួយរក្សានូវការពារសេចក្តីសុខចំពោះគ្នានឹងគ្នាៗ ក្នុងចំណោមមនុស្សទាំងនោះ មានជនជាច្រើនដែលមានកាំភ្លើងនឹងគ្រាប់រំសេវសំរាប់ការពារខ្លួន គេមិនខ្លាចតែត្រឹមចោរប្លន់ឡើយ គេត្រូវប្រារព្ធដល់ពួកទាហាននៃកងការក្រុងស្តង់ទីណុបទៀតៗ

កាលណោះ សាយណ្ហសម័យការនៃតនទៅបម្ដិចម្ដងៗនារីពីរនាក់កៀងសន្ទ្រឹមៗនូវពពែមួយហ្វូងតូច សំដៅទីស្នាក់ៗ គឺជាយុវតីពីរនាក់ មួយអាយុដប់ប្រាំបីឆ្នាំ មួយម្ភៃឆ្នាំៗ នាងដែលនៅក្មេងជាងឈ្មោះឡូឡា, នាងបងឈ្មោះអាតស្យាតាៗ នាងបង ពិតមែនតែអាយុច្រើន ប៉ុន្តែត្រូវបណ្ដោយឲ្យប្អូនដឹកដៃដូចជាកូនក្មេងតូច ដ្បិតនាងមានភ្នែកងងឹតៗ អាតស្យាតាភ្នែកខ្វាក់ទាំងសងខាងៗ

សេចក្តីទុក្ខនេះហើយដែលបណ្តាលឲ្យលោកគាម៉ាព្រេក មានសេចក្តីអាសូរខ្លាំងក្នុងខណៈដែលម្តាយនាងឈ្មោះ ចាដ្យា មកអង្វរសុំឲ្យលោកមេត្តាទទួលគាបីនាក់ឲ្យនៅក្នុងពួកលោកផង ខាងក្រោយមរណភាពរបស់ប្តីនាងៗ នាងតែងនាំហ្វូងពពែតាមផងជានិច្ចគ្រាន់នឹងបានទឹកដោះឬកូនពពែអាស្រ័យៗ ចំណែកនាងចាដ្យាជាម្តាយទទួលខ្លួនជាអ្នកស្ងួ ដណ្តាំសម្រាប់ប្រុស ១ៗ ឯនាងឡូឡាធ្លាតខាងដេរប៉ាក់សំពត់យ៉ាងពេក

ទឹងសែសយមាស ឬក៏ដេរខ្នើយពូកដោយស្បែកដែលគេតែងយកទៅលក់ជូនអាម៉ឺនចាស់ស្រុកក្នុងទីក្រុង ។ ការរស់នៅយូរនឹងការមានសេចក្ដីពិសោធន៍ច្រើន ធ្វើឲ្យលោកតាម៉ាត្រពកមានចិត្តសប្បុរស ហើយព្រមទទួលស្រីបីនាក់នេះភ្លាម មិនបានពិនិត្យយូរ ៗ ហើយស្រីទាំងបីនាក់គឺម្ដាយនឹងធីតាមិនជាយូរប៉ុន្មាន បានជាទីពេញចិត្តនៃមនុស្សទាំងអស់ ៗ នាងអាឥស្សរាតា ពិតមែនតែមានសេចក្ដីទុក្ខព្រួយជាប់នៅក្នុងចិត្តជានិច្ច គង់បេះសំដែងអាការស្លូតបូតនឹងសេចក្ដីរីករាយ ដែលអាចញ៉ាំងសេចក្ដីមេត្រីនៃលោកតាម៉ាត្រពកឲ្យកម្រើកបាន ៗ ចំណែកនាងឡីឡាវិញនោះ ឧបមាដូចផ្កាកំពុងរីកកណ្ដាលព្រះសូរ្យា ៗ

គឺនារីនេះហើយដែលជាសេចក្ដីរីករាយរបស់មនុស្សទាំងអស់ ហើយកាលណាព្រឹមកដល់ មានដុតចង្កៀងក្លីក្រហមព្រោងព្រាតលើពលឡាប់, ពួកអ្នកដើរទេសទាំងប៉ុន្មានអង្វរសុំឲ្យនាងរើសទំនុកច្រៀងអាពាប់ណាមួយដ៏ពីរោះស្រងេះស្រងោចមកច្រៀងឲ្យស្ដាប់ ៗ ក្នុងអាកាសយប់ស្ងាត់ សូរចម្រៀងលាន់ត្រលួចឡើងសំដៅផ្កាយទាំងឡាយ, ចំណែកមនុស្សទាំងឡាយនាំគ្នាស្ដាប់កាំងភ្លេចសេចក្ដីលំបាក សេចក្ដីនឿយហត់នឹងសេចក្ដីទុក្ខ ដើម្បីផ្ចាប់ដួងវិញ្ញាណជាមួយនឹងសូរសៀងរបស់នាងក្រមុំឡីឡា ៗ

នាងឡីឡាប្រកបដោយរូបសម្បត្តិ នឹងសម្ផស្សសម្បត្តិ ៗ ក្នុងពីរខ្មៅយង់មានកេសាវែង ប្រក់ពីលើ ជាទីធ្វើមុខមូលទ្រវែងពាសពេញ

ទៅដោយពេមស្តើងៗ ទន់ល្មើយ ឲ្យស្រស់ឡើងអស្ចារ្យ ។ ឡីឡា មិនធំ មិនតូច យ៉ាងសម បង្កេះមូលក្តុំ ស៊ុទីងដងខ្លួន តែងញ៉ាំងបុរស ឲ្យរំភើបចិត្តជានិច្ច, វេលាដែលនាងដើរទៅមកកាត់ជុំ ដំណើរបង់ ប្រាយសមទីងពង ត្រូវគ្នានឹងក្រមាទទូរសាច់ទន់ នាងតែងញ៉ាំងតម្រេក ឲ្យកើតឡើងតាមជាន ជាតម្រេកដែលនាងគ្មានបំណង ព្រោះនាងមិន ទាន់ចេះគុំបតែងខ្លួនទៅឡើយ ។

នាងឡីឡា បើនាងលោជាទឹកឡើង តែងទឹកខុសពីអ្នកផងទាំងពួង គឺនាងទឹកដល់រឿងដ៏ធំស្មើរហួសវិស័យក្នុងប្រវត្តិរបស់នាង ។

តាំងពីក្មេងមក នាងតែងជាប់ចិត្តចំពោះរឿងព្រេងដែលជីដូននាង ឧស្សាហ៍និយាយប្រាប់ គឺអំពីសុល្តាន អំពីកាអ៊ិត អំពីព្រះអង្គម្ចាស់ អំពីមេចំបាំងផ្សេងៗ ហើយនាងតែងរក្សាបឋមជវ័នទុកក្នុងដួងហទយៈ យ៉ាងមាំ ខុសអំពីស្រីៗ ជាគូកនក្នុងស្រុកកំណើតជាមួយ ។ ការតម្រេក ខ្លីខ្លាមិនដែលកើតមានដល់នាងម្តងទេ ហើយបើលោជាទឹក នាងទឹកឲ្យ បានដូចក្នុងរឿង គឺជាស្តេច ព្រះអង្គម្ចាស់ ឬមេចំបាំង ណាមួយរូប យ៉ាងធេត ជិះសេះមកនិយាយសំដីទន់ផ្អែម ហើយលើកនាងឲ្យអង្គុយ នៅលើសេះជាមួយ រួចបនាំសំដៅពាំងប្រាសាទ បរិបូណ៌ដោយទឹកថ្ម ត្រជាក់ ដោយគ្រឿងក្រអូបឈ្ងុយឈ្ងប់ ដោយគ្រឿងសំលៀកបំពាក់ សុទ្ធតែព្រែ ដោយកែវកង មាសប្រាក់ ពេជ្រ មិនមានខ្វះ ។

(មានត)

# ការសន្ទនាពីសិល្បៈខ្មែរ

## លើកទី ១

# របស់លោក ចាប-ពិន

---

កាលពីថ្ងៃទី ៧ ខែធ្នូ ព.ស. ២៤៩៦ គ.ស. ១៩៥៣

ឯ. ឧ. សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ និងការសិក្សាធម៌វិន័យខាងព្រះពុទ្ធសាសនា បានអញ្ជើញទៅជួបសន្ទនាជាមួយនឹង ឯ. ឧ. ប៉ាក់-សារិន អនុរដ្ឋលេខាធិការទទួលបន្ទុកខាងឃោសនាការ ស្នើយោបល់ថា "ឯ. ឧ. មានមធ្យោបាយយ៉ាងណាខ្លះដែលជាទីនាំឲ្យចំរើនសិល្បៈខ្មែរយើងតទៅ?" ។

ឯ. ឧ. ប៉ាក់-សារិន តបថា: រូបខ្ញុំដែលមកទទួលបន្ទុកឃោសនាការថ្មីៗនេះ យល់ឃើញថា សិល្បៈខ្មែរយើង បើពោលឲ្យខ្លី មានភ្លេងនិងចម្រៀងជាដើមនេះ ជាមធ្យោបាយយ៉ាងប្រពៃ ក្នុងផ្លូវឃោសនា អាចណែនាំប្រជាជនរួមជាតិ ឲ្យងាកទៅរកសាមគ្គីធម៌ឲ្យចេះស្រឡាញ់ជាតិ សាសនា មហាក្សត្រ ព្រមទាំងឲ្យចំរើនភាសាអក្សរសាស្ត្រឲ្យប្រទេសជាតិបែរមុខទៅកាន់វឌ្ឍនភាពបានប្រសិនបើចេះសម្រួល ប៉ុន្តែបើបោះបង់មិនសម្រួលឲ្យសមតាមកាលៈទេសៈទេ នឹងអាចនាំឲ្យបែរទៅកាន់ផ្លូវផ្ទុយពីនេះទៅវិញដោយពិត ។ ព្រោះហេតុដូច្នេះហើយ បានជាខ្ញុំកំពុងគិតកែសម្រួលនូវភ្លេងនិងចម្រៀងឲ្យបានស្រួល ដើម្បីនឹងឲ្យ

ផ្សាយតាមវិទ្យុកម្ពុជា ជាសំឡេងដែលនាំប្រជាជនរួមជាតិយើងឲ្យបែរមុខទៅរកវឌ្ឍនភាព ។

ង.១. សម-ញាណ គបថាៈ យោបល់ ង.១. យល់ឃើញយ៉ាងនេះល្អប្រសើរណាស់ ព្រោះសំឡេងដែលផ្សាយតាមវិទ្យុឃោសនស័ព្ទនេះឮខ្ទរទៅពេញប្រទេសយើង ប្រជាជនរួមជាតិរមែងស្តាប់ច្រើនគ្នា កាលបើឮក្មេងឮសំឡេងច្រៀង ត្រង់ចំនុចណាមួយមានប្រយោជន៍ដល់ប្រទេសជាតិ ក៏មុខជាចាំបានយកទុកជាគតិ ដោយរកពុំខាន ប៉ុន្តែមិនអាចធ្វើក្នុងពេលខ្លីបានទេ លុះត្រាតែព្យាយាមធ្វើយូរអង្វែងទៅអនាគតឲ្យជ្រួតជ្រាបដល់ដួងចិត្តប្រជាជនរួមជាតិនោះទើបបាន ។ រីឯចំនុចដែលមានសារប្រយោជន៍ គួរយកមកផ្សាយតទៅនោះប្រសិនបើ ង.១ លើកយកអត្ថបទក្នុងសៀវភៅចម្រៀងជាតិនិយម ខ្សែទី ១ មកឲ្យអ្នកចម្រៀងច្រៀងផ្សាយទៅនោះ មុខជាប្រជាជនរួមជាតិយើងចូលចិត្តស្តាប់ ហើយចង់ចាំទុកជាគតិតទៅ ។ ដោយហេតុថាចម្រៀងជាតិនិយមនោះ ជាកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ដោយគណៈធម្មការគីតនិពន្ធ របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ បានប្រជុំអស់លោកអ្នកដែលចេះដឹងស្គាល់ប្រយោជន៍ខាងផ្លូវលោក និងផ្លូវធម៌ រៀបរៀងឡើងដោយពិនិត្យពិច័យ បានបោះពុម្ពពី ព.ស. ២៤៩៤ គ.ស. ១៩៥១ ចំនួន ២០០០ ក្បាល ផ្សាយនៅក្នុងប្រទេសយើង តាំងបាន

ចេញទៅប្រទេសក្រៅអស់ជាច្រើនក្បាល ហើយមាននៅសល់ខ្លះ ទុកជាជូនប្រជាជនគេទៅ, ខ្ញុំយកសៀវភៅចម្រៀងជាតិនិយមខ្មែរ ១ មួយក្បាលនេះមកជូន ឯ. ឧ. ប្រើការកែងរៀសំឡេងប្រទេសកម្ពុជា ជាប្រយោជន៍ដល់ប្រជាជនខេមរជាតិ ។

ឯ. ឧ. ប្រាក់ សារិន ទទួលដោយរីករាយហើយមានប្រសាសន៍ថា: សៀវភៅនេះ ខ្ញុំបានទទួលពីពុទ្ធសាសនបណ្ឌិត្យ ១ ក្បាលដែរ ឃើញចំនុកណែនាំប្រជាជនឲ្យចេះដឹងនូវករណីយកិច្ចរបស់ពលរដ្ឋ ស្រុវតែចម្រៀងមានសារប្រយោជន៍ល្អៗមែន ខ្ញុំនឹងចាត់ឲ្យយកទៅច្រៀងជាក់វិទ្យុកម្ពុជាជាបន្ត ។ ត្រាតែចប់ ដោយលៃលកចែកពេលឲ្យលេងភ្លេងចម្រៀងតាមសម័យថ្មីខ្លះ តាមបែបបទក្បួនធម៌ដែលប្រទេសយើងជ្រើសទុកជាទំនៀមទម្លាប់ដកបមកខ្លះ ។ ឯសាច់ភ្លេងនឹងឲ្យប្រើបាប៉ុខ្លះ សាយដៀវខ្លះ, ចំណែកបទនឹងប្រើបទសាកំមេ ផាត់ជាយ ឬផាត់ជាយក្លាយជាដើម ។ មិនគ្រាន់តែឲ្យច្រៀងហើយបោះបង់ចោលទេ ខ្ញុំនឹងពិនិត្យមើល កាលបើឃើញថាចម្រៀងណាមួយមានចំនុកល្អហើយពីរោះផងនោះ ខ្ញុំនឹងចាត់ឲ្យថតសំឡេងចម្រៀងនោះ ទុកផ្សាយក្នុងប្រទេសយើង ព្រមទាំងឲ្យផ្សាយចេញទៅប្រទេសដទៃៗផងទៀត ។

ឯ. ឧ. សម ញាណ តបថា: ប្រពៃណាស់ អំពើដែល ឯ. ឧ. ប្រងរៀបចំនេះ ប៉ុន្តែសិល្បការខ្មែរ មានភ្លេងនឹងចម្រៀងជាដើមនេះ

នឹងមានរសជាតិល្អទៅបានមកពីអ្នករៀង បេះប្រើពាក្យពេចន៍ឲ្យស្របតាមគោលវេយ្យាករណ៍ ពោលឲ្យច្បាស់ឲ្យស្ដាប់បានស្គាល់ថាជាសំឡេងខ្មែរសំដីខ្មែរ ព្រមទាំងពោលឲ្យត្រូវតាមពាក្យដែលប្រើជាផ្លូវការកុំឲ្យល្អៀង ដូចតែងបានឮញយ៉ៗ មកហើយ គឺ

- អាណិត ទៅជា រណិត
- អាល័យ — រាំឡៃ
- រលឹក — អាលឹក
- បាលី — ប្រឡី ជាដើម ។

ហេតុនេះត្រូវឲ្យលោកអ្នករៀងពិនិត្យមើលពាក្យតាមសៀវភៅនោះរៀងកុំឲ្យល្អៀង, ប្រសិនបើលោកអ្នករៀងណាមួយ មិនយល់ពាក្យត្រង់ណាមួយ ឬសង្ស័យពីអ្វីមួយក្នុងចំណោមបម្រៀងខ្មែរនេះសូម ឯ.ឧ. ចាត់ឲ្យអ្នករៀងនោះទៅជួបនឹងលោក ចាប-ពិន នាយការិយាល័យចំរៀងទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ លោកនេះនឹងរាប់រងពន្យល់ជូនដោយមេត្រីភាពដ៏ស្និទ្ធ គ្រប់តែពេលធ្វើការ ដើម្បីឲ្យសម្រេចតាមគោលបំណងដ៏ប្រសើររបស់ ឯ.ឧ.តទៅ ។

ឯ. ឧ. ប្រាក់ · សារិន តបថា: សាធុប្រពៃណាស់ បើដូច្នេះសង្ឃឹមថាបំណងរបស់ខ្ញុំមុខជាបានស្រួលហើយសម្រេចតៗទៅពុំខាន ។

ការសន្ទនាពីសិល្បៈខ្មែរ របស់ ឯ. ឧ. ទាំងពីររូបចប់ដោយព្រមព្រៀងស្របយោបល់គ្នាត្រឹមប៉ុណ្ណេះ ។

*
* *

សូមឧកាសបន្តសេចក្ដី :

យុនឧត្ដមប្រឹជា ថាប ពិន ខ្ញុំជានាយការិយាល័យចំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិត្យ កាលបើបានព្ទកិច្ចសន្ទនារបស់ ឯ ឧ. ទាំងពីររូបព្រមទាំងដឹងនូវការព្រមព្រៀងនេះហើយ ក៏ពេញទៅដោយសោមនស្សរំភើបចិត្តយ៉ាងក្រៃលែង ។ មិនត្រឹមតែរូបខ្ញុំម្នាក់ឯងទេ អស់លោកអ្នករៀបរៀងចម្រៀងជាតិនិយមគ្រប់គ្នា ដូចមាននាមបុះកង អារម្មកថាសៀវភៅចម្រៀងជាតិនិយមខ្សែទី ១ ក៏មានចិត្តត្រេកអរហើយកើតចិត្តឧស្សាហ៍មានបំណងថា: កាលបើ ឯ. ឧ. ហៅក្រសួងឃោសនាការចាត់ឲ្យច្រៀងតាមរឿងនិពន្ធក្នុងសៀវភៅចម្រៀងជាតិនិយម ជិតអស់ក្នុងសៀវភៅទី ១ នោះ ពេលណា នឹងរួបរួមគ្នារៀបរៀងទំនុកច្រៀងតទៅជាសៀវភៅខ្សែទី ២ ទី ៣ ក្នុងពេលនោះតទៅទៀត ដើម្បីផ្សាយនូវចម្រៀងជាអគ្គការសិល្បៈខ្មែរ ឲ្យសមតាមឋានៈប្រទេសកម្ពុជាដែលបានឯករាជ្យ ដោយថ្វីព្រះហស្តនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង មិនឲ្យអួនថយជាងប្រទេសដទៃឡើយ ។

ឱ ហ្ន៎! សេចក្តីសាមគ្គីព្រមព្រៀងបែរទៅកាន់គោលនៃការចំរើន មានដំឡៃអ្វីម៉្លេះហើយ! គ្រាន់តែការដែល ឯ. ឧ. ចៅក្រសួងទាំងពីររូប ព្រមព្រៀងគ្នាប៉ុណ្ណោះនេះ នាំឲ្យយើងរំភើបចិត្តព្រមទាំងមានឧស្សាហ៍ មានចិត្តខ្នះខ្នែងចូលជួយក្នុងការកសាងប្រទេសជាតិទ្វេឡើង ទុកជាការតបស្នងនូវព្រះមហាករុណាធិគុណនៃព្រះប្រិយមហាវីរក្សត្រតរៀងទៅ ។

កាលបើចិត្តយើងបានស្ទុះឡើងយ៉ាងនេះ ក៏មានសេចក្តីសង្ស័យ ថាក្រែងមិនសម្រេចដូច្នេះទេដឹង ។

អារម្មណ៍នេះស្របចូលក្នុងចិត្តយើង ឲ្យយើងត្រៀមចាំមើល, ស្រាប់តែមានបង្គាប់ពី ឯ. ឧ. រដ្ឋមន្ត្រីក្រសួងធម្មការថា: ឯ. ឧ ចៅក្រសួងឃោសនាការតម្រូវឲ្យច្រៀងតាមទំនុកនៃចម្រៀងជាតិនិយម នៅថ្ងៃទី ៣១ ខែកក ព. ស. ២៤៩៦ គ. ស. ១៩៥៤ នេះ ជាលើកដំបូងបំផុត ទើបចាត់រូបខ្ញុំជានាយការិយាល័យនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ឲ្យចូលមកថ្លែងព្រឹត្តិការសន្ទនាពីសិល្ប:ខ្មែរនេះ ដូចបានពណ៌នាមកពីខាងលើរួចហើយ ។

បន្ទាប់ពីការសន្ទនាមក ឯ. ឧ ចៅក្រសួងធម្មការ សិល្បការ និង ឯ. ឧ. ចៅក្រសួងឃោសនាការបានចាត់ហ្វូងភេហារ ថែម និងនាង សម្បត្តិ ឲ្យច្រៀងតាប៉ុ ចោទឆ្លើយគ្នាតាមទំនុកច្រៀងក្នុងសៀវភៅចម្រៀងជាតិនិយមរបស់ពុទ្ធសាសនបណ្ឌិត្យ ដាក់វិទ្យុសម្លេងប្រទេស

កម្ពុជានៅថ្ងៃទី ៣១ មករា ១៩៥៤ ជាសណ្ដាប់អស់បងប្អូនរួមជាតិ ដើម្បីគេព្រាកគន្លងគតិសិល្បៈខ្មែរ ឲ្យគង់វង្សនិងពង្រីកឲ្យកាន់តែប្រសើរឡើងជាកិច្ចការតទៅ ។

បរិយាយពីសិល្បៈខ្មែរ

លើកទី ២

របស់លោក ចាប-ពិន

កាលពីថ្ងៃទី ៣១ មករា ១៩៥៤ នេះ ខ្ញុំបានបរិយាយពីការសន្ទនារវាងឯកឧត្តមទាំងពីររូប គឺឯកឧត្តម សម-ញាណ នៅក្រសួងធម្មការ-សិល្បការ និងឯកឧត្តម ប្រាក់ សារិន នៅក្រសួងឃោសនាការ អំពីសិល្បៈខ្មែរ ជូនជាសណ្ដាប់បងប្អូនរួមជាតិជាទីស្រឡាញ់ម្ដងហើយ, ឥឡូវនេះ ខ្ញុំបានកិត្តិយសបរិយាយពីសិល្បៈខ្មែរមួយបែបផ្សេងពីនោះជាលើកទី ២ ជូនម្ដងទៀត មានសេចក្ដីដូចតទៅនេះ :

ការរាំ ការច្រៀង និងភ្លេង បើហៅដោយផ្នែកៗ ការរាំ ជានាដសិល្បៈ, ការច្រៀង ជាគីតសិល្បៈ, ភ្លេង ជាតូរ្យាន្តសិល្បៈ, បើហៅដោយរួមទាំង ៣ ផ្នែកថា "នាដសិល្បៈ" តែម្យ៉ាង ។ សិល្បៈទាំង ៣ ផ្នែកនេះ ជាសិល្បៈតែងមានប្រចាំជាតិ ប្រចាំប្រទេសរៀងរាល់ជាតិ រាល់ប្រទេស ទូទៅទាំងសាកលលោក ហើយជាសិល្បៈដែលមានជាប់ជាពូជជាគេៗ តាំងពីព្រេងនាយមក ។ សិល្បៈទាំងនេះកាល

កើតឡើងដំបូងនៅទន់ខ្សោយ នៅឡើយទេ តមកទើបគេសន្សឹមៗកែខៃផ្លាស់ប្តូរបែបផែនឡើងបន្តិចម្តងៗជាលំដាប់ ដោយគេលើកដំកើងរាប់អានតៗគ្នា ជាច្រើនដំណអាយុមនុស្សរៀងរាល់ប្រទេស ទាល់តែបានសំរេចរូបជាសិល្បៈត្រឹមត្រូវល្អបរិបូណ៌ពេញលក្ខណៈ សម្រាប់ប្រទេសនីមួយៗ ដែលនឹងផ្លាស់ប្តូរកែខៃពុំបាន ក្រៅពីការបាត់បង់រូបដើម ហើយនឹងកើតថ្មីជាបែបមួយផ្សេងទៀត ។

ធម្មតាសិល្បៈ មិនថាជាតិណាទេ កាលបើគេរៀបចំកែខៃតៗគ្នាដរាបដល់បានសម្រេចរូបត្រឹមត្រូវល្អ បរិបូណ៌ផុតថ្នាក់ ដែលតាមភាសាបារាំង គេហៅថា សិល្បៈក្លាសុិកឡើងហើយ សំគាល់ថាជាសិល្បៈដែលចម្រើនដល់ថ្នាក់បុងកំពូលបំផុត ។ សិល្បៈរបស់ជាតិណាក៏ដោយកាលបើបានចម្រើនដល់ថ្នាក់ក្លាសុិកហើយក៏តែងតែសន្សឹមៗ សាបសូន្យទៅវិញ ព្រោះកែខៃឲ្យល្អជាយ៉ាងម្តេចទៅទៀតពុំបាន; ហេតុនេះបានជាជាតិដែលចម្រើន គេតែងតែហួងហែងនិងព្យាយាមថែរក្សានូវសិល្បៈក្លាសុិករបស់គេទុកមិនឲ្យសាបសូន្យទៅរហ័ស ព្រោះសិល្បៈក្លាសុិករបស់ជាតិជាគ្រឿងសំគាល់នឹងជាភ្នែកប្រមុះរបស់ជាតិ ដូចគ្នានឹងកញ្ចក់ឆ្លុះសម្រាប់ឆ្លុះបញ្ចាំងនិស្ស័យចិត្តនឹងព្រឹត្តិការរួមគ្នារបស់ប្រជាជន ឲ្យសាកលលោកបានឃើញច្បាស់ថាមិនមែនជាជាតិព្រៃផ្សៃ ទាំងមិនមែនជាតិទើបកើតថ្មីដែលឥតមានអ្វីល្អជាសម្បត្តិសម្រាប់ជាតិ របស់ខ្លួន

គឺឲ្យដឹងថាជាតិមានសម្បត្តិជាមត៌កតៗ គ្នាមកអំពីអតីតកាល ។ សេចក្តីសង្ឃឹមរបស់ជាតិ មិនមែននៅត្រង់បច្ចុប្បន្នចំពោះមុខទេ គឺនៅក្នុងអនាគត ហើយនឹងនៅត្រង់ប្រជាជនចេះថែរក្សាកេរ្តិ៍ដំណែលដ៏ល្អៗ របស់ជាតិក្នុងអតីតកាលទុកយ៉ាងខ្ជាប់ខ្ជួន ទាំងចេះផ្លាស់ប្តូរកែខៃរបស់ចាស់ឲ្យឈមមុខសមរម្យទៅតាមកាលសម័យ ។

គ្រឿងសំគាល់ដែលសំដែងឲ្យឃើញសេចក្តីទាបខ្ពស់របស់ជាតិនៅត្រង់វប្បធម៌, នាដសិល្ប: គីតសិល្ប: និងតុរ្យាង្គសិល្ប: ក៏ជាចំណែកមួយៗ របស់វប្បធម៌, យើងនឹងស្ទង់មើលជាតិណា ថាមានសេចក្តីចម្រើននៅក្នុងថ្នាក់ជាន់ទាប ឬ ជាន់ខ្ពស់ត្រឹមណា ក៏អាចស្ទង់មើលបានដោយការកំការប្រៀងនឹងភ្លេងតូរ្យតន្ត្រី ដែលប្រជាជនពប់អានទូទៅទាំងមហាសង្គមក្នុងប្រទេស, បើយើងធ្វើដំណើរទៅបរទេស យើងបានឃើញល្បាំរបស់ជាតិណា ដែលគេពប់អានថាជាសេរីជាតិរបស់គេ យើងអាចវាស់សេចក្តីចម្រើនរបស់ជាតិនោះបានភ្លាមៗ ថា គេមានសេចក្តីចម្រើនដោយវប្បធម៌ និងអារ្យធម៌ត្រឹមថ្នាក់ណា ។

មហោស្រពខ្មែរ ជានាដសិល្ប:របស់ខ្មែរយើងទាំងជាសិល្ប:ដែលកើតមានឡើងតាំងពីរជ្ជកាលព្រះបាទជយវរ្ម័នទី ២ គឺព្រះកេតុមាលា, សម័យអង្គរ រវាងពុទ្ធសករាជ ១៣៤៥ ដល់ ១៣៩៧ គ្រិស្តសករាជ ៨០៣ ដល់ ៨៥៥ មកម្ល៉េះ ហើយចម្រើនឡើងជាលំដាប់ដពបដល់បាន

ជានាដសិល្បៈក្លាសិករបស់ខ្មែរ ជាវប្បធម៌ខ្មែរ បុព្វបុរសរបស់ខ្មែរ យើងបានថែរក្សាវប្បធម៌នេះទុកឲ្យគង់វង្សជាពូជធារដកបមកដល់យើងជាកូនចៅសព្វថ្ងៃ ។

ចំណែកគីតសិល្បៈ ពួកគីតសិល្បិនអ្នកសំដែងសិល្បៈខាងចម្រៀងខ្មែរយើងក៏ធ្លាប់ជំនាញខាងច្រៀង មានចម្រៀងតាមប៉ុជាដើមតាំងពីបុរាណព្រេងនាយមកតាមលំដាប់រជ្ជកាល, មានអ្នកច្រៀងតាមប៉ុជំនាញៗ ជាច្រើននាក់ ខាងពួកប្រុសៗដូចគេដន្ទ្រា សរ, សុភាព្រហ្ម, គិរម្យណុះ ជាដើម ដល់មករជ្ជកាលព្រះករុណា សុរាំណ្ណកោដ្ឋ អាឡាក់ប៉ែន, រជ្ជកាលព្រះករុណា សុរាំណ្ណកោដ្ឋ និងព្រះពជានុកោដ្ឋ ជំងប់សាន់, គិរម្យង៉ុយ នឹងសូរសៀងពៅ, ខាងពួកស្រីៗ នាងសូរ យ៉ែម, សូរ·យឹម, ឌូច វ៉ង សាពៅយន្ទួន, កែមបូផា, កែវសូរិកាន នឹងសាអ៊ុជុំខែត្រ ជាដើម សុទ្ធតែជាអ្នកច្រៀងតាមប៉ុគ្គា ប្អូម្នាក់ៗ យ៉ាងឯកៗ ប៉ុកកែគិរម្យង៉ុយមួយជាអ្នកៈច្រៀងសាយដៀវយ៉ាងល្បីល្បាញ បានទៅច្រៀងថ្វាយព្រះចៅថៃឯក្រុងបាងកកផង បានទទួលសេចក្តីសរសើរជាច្រើន ។

គួរឲ្យស្តាយណាស់ដែលសម័យបច្ចុប្បន្ននេះ ប្រទេសខ្មែរយើងនៅសល់អ្នកច្រៀងតាមប៉ុតិចគ្នាពេក ។

ព្រោះហេតុនេះ បានជាឯកឧត្ដម ទៅក្រសួងធម្មការសិល្បការ ទាំងឯកឧត្ដម ទៅក្រសួងឃោសនាការ ប្រាថ្នាទាំងពង្រីកហើយទាំងរក្សាទុកនូវសិល្បៈខ្មែរ ឲ្យរីកសាយឲ្យគង់វង្ស បានចាត់ហ្វឹកហាត់ សែម ឲ្យរៀនចាប៉ីជាកិច្ចសំឡេងប្រទេសកម្ពុជា នៅថ្ងៃទី ១០ កុម្ភៈ ១៩៥៤ តាមអត្ថបទក្នុងសៀវភៅចម្រៀងជាតិនិយម ដែលបានបោះពុម្ពហើយ មានផ្សាយសព្វថ្ងៃនេះ ។ (មានត)

## និគមវចនៈនៃការបរិយាយខាងដើម

កម្ពុជរដ្ឋជាប្រទេស
ធ្លាប់ថ្កើងវិសេសដល់ឋានៈ
ក្លាស៊ិកខាងល្បាំជាតិខេមរៈ
ដ៏ជាសិល្បៈខ្មែរបុរាណ ។
ពួកខ្មែរសម័យគួរស្រុះគ្នា
ព្យាយាមសិក្សាឲ្យចំណាន
វិជ្ជាសិល្បៈទាំងប៉ុន្មាន
ឲ្យខ្មែរថ្កើងថ្កានតទៅអើយ !

ចាប - ពិន

## ការប្រឡងបេក្ខបព្វជិតដែលក្រសាំងស៊ីន
ដើម្បីជ្រើសឲ្យចូលរៀនក្នុងឋានៈជាសិស្សស្តាប់នៅសាលាបាលីជាន់ខ្ពស់

## ព្រះញាណកោសលញាណ-ឈឹន វៀបរៀង

---

ការប្រឡងជ្រើសរើសពួកនិស្សិតបព្វជិត ដែលមានសញ្ញាបត្រសាលាបាលីរងដែនក្រសាំងស៊ីន ដូចមានតទៅនេះ៖

កាលពីថ្ងៃទី ២៦ ដល់ ២៨ ខែកុម្ភៈ ឆ្នាំ ១៩៥៤ នៅសាលាបាលីរងវត្តសាកវ័នតេជោ ភ្នំពេញ មានការជួបជុំពួកព្រះសង្ឃមេប្រយោគនិងសិស្សដែលបំរុងប្រឡង ដើម្បីចូលរៀនក្នុងឋានៈជាសិស្សស្តាប់នៅសាលាបាលីជាន់ខ្ពស់ ក្រោមការទំនុកបំរុងរបស់លោកឡាំ-ឯម អតីតចៅហ្វាយខេត្រឃាំង ហើយជាអធិបតីរងនៃពុទ្ធសាសនបណ្ឌិត្យដែនក្រសាំងស៊ីន តាមប្រកាសលោកគូវែរណឺហ្ស៊េណេរាលលេខ ៣៨៥០ ចុះថ្ងៃ ២៥ កញ្ញា ឆ្នាំ ១៩៤៣ អនុញ្ញាតឲ្យតាំងក្រសួងពុទ្ធសាសនបណ្ឌិត្យរង នៅប្រទេសវៀតណាម ក្រសាំងស៊ីនប៉ែកខាងត្បូង ។

ការប្រឡងនោះ ធ្វើនៅពេលព្រឹកចាប់ពីម៉ោង ៨ ដល់ម៉ោង ១១ និង ៣០ នាទី និងវេលារសៀលតាំងពីម៉ោង ១៥ ដល់ម៉ោង ១៨ ថ្ងៃខាងលើនោះ, ក្រុមសន្និបាតមានសមាសភាពដូចតទៅនេះគឺ

១ – ព្រះញាណកោសល ញាណ · ឈឹន វត្តលង្កា អធិបតី

២ – ព្រះត្រៃមុនីសោភ័ណ សេក · នាង វត្តខណ្ណាលោម សមាជិក

៣- ព្រះបាឡាត់ឃោសវគ្គិត ហ៊ុយ-អ៊ួច វត្តសាកវ៉ន សមាជិក
៤- ព្រះមហា វិញ-គៀង ជុំ " ឧណ្ណាលោម "
៥- " ថាច់-ឯក " សាកវ៉ន "
៦- " ខេមរិន្ទ " មហាមន្ត្រី "
៧- " ជា-អៀន " លង្កា លេខាធិការ ។

តាំង ៧ អង្គនេះបានជួបជុំតាមកាលបរិច្ឆេទដូចខាងលើ រួចហើយទើបលោកអធិបតីរង់នៃពុទ្ធសាសនបណ្ឌិត្យ ប្រគល់វិញ្ញាសាប្រឡងទាំង៥ប្រយោគ ដែលប្រកស្រោមបិទភាគល័ខយ៉ាងជិតស្និទ្ធឥតមានរង្កៀស ប្រគេនទៅលោកអធិបតីមេប្រយោគៗក៏បើកឧកាសប្រឡងសិស្សចំនួន ៤២ រូបដែលអង្គុយតាមលំដាប់លេខរៀងសម្រាប់ខ្លួន តាំងពីលេខ ១ ដល់ ៤២, ទើបលោកមេប្រយោគបើកវិញ្ញាសាបង្ហាញ រួចហើយហៅឲ្យសរសេរតាមសូត្រ, លំដាប់តមកឲ្យសិស្សប្រែបាលីលោតប្រយោគ, អធិប្បាយគាថា, តែងសេចក្តីខ្មែរ, ឆ្លើយចំណោទពុទ្ធ ។ ទាំង៥ប្រយោគនេះសុទ្ធតែសរសេរទាំងអស់ ឥតមានសួរផ្ទាល់មាត់ទេ ។ ក្រដាសប្រឡងទាំងនោះសឹងបិទនាមសាមីខ្លួនអ្នកប្រឡងយ៉ាងជិតតាមបញ្ញត្តិច្បាប់ ។ លុះសិស្សសរសេររួចពល់ទាំង ៥ ប្រយោគហើយក្រុមមេប្រយោគពិនិត្យតាមកម្លាំងប្រាជ្ញារបស់សិស្ស ដែលជាប់នៅនឹងក្រដាសរួចហើយឲ្យពិន្ទុ ពីសូន្យដល់ម្ភៃ (២០), សិស្សដែលបានពិន្ទុបូករួមយ៉ាងតិចត្រឹម ១១០ ពិន្ទុ ទើបទុកជាបានការ ។

# លទ្ធផល

បណ្ដាសិស្សទាំង ៤២ រូប ដែលបានចូលប្រឡងតាំងពេលព្រឹក ល្ងាចក្នុងថ្ងៃដូចខាងលើ លុះរួចរាល់ហើយ ចំនួនសិស្សដែលមានពិន្ទុគួរដល់ការ មានតែចំនួន ២០ រូប ដូចមានរាយនាមក្នុងបញ្ជី និងសេចក្ដីកត់ហេតុ ជូនទៅលោកអធិបតីរងនៃពុទ្ធសាសនបណ្ឌិត្យសព្វគ្រប់ស្រាប់ក្នុងទីនេះ មិនបានសរសេររាយនាមទៀតទេ ។

សូមសរសើរយោបល់នៃក្រសួងពុទ្ធសាសនបណ្ឌិត្យរង និងសមាគមសិក្សាវិទ្យាល័យៈខេមរៈដែនកូសាំងស៊ីន ដែលមានលោកឡាំ-ឯម ជាប្រមុខ ចេះរៀបចំធ្វើការបណ្ដុះបណ្ដាំអក្សរសាស្ត្រ, វប្បធម៌, អារ្យធម៌, រក្សាទំនៀមទម្លាប់របស់ខេមរវង្សឲ្យរស់នៅរវើកក្នុងទីបន្ទៀត ដរាបដល់សព្វថ្ងៃនេះ ជាអំពើដ៏ប្រសើររកបានដោយក្រក្នុងលោកមួយ ។

សូមជូនសព្ទសាធុការពរ ចំពោះបងប្អូនរួមជាតិដែនកូសាំងស៊ីនទាំងព្រះសង្ឃគ្រហស្ថ ឲ្យបានសុខចំរើនសព្វៗកាល ។

សួស្ដីខ្មែរដែនកូសាំងស៊ីន!

ធ្វើនៅថ្ងៃ ២៨ កុម្ភៈ ១៩៥៤

---